ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអនុវត្ត

# គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ

# ឆ្នាំ២០១៩-២០២៩

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

រាជធានីភ្នំពេញ ឆ្នាំ២០២១

ក្រុមការងារបច្ចេកទេសអន្តរក្រសួង
នៃគណៈកម្មការការពារកុមារថ្នាក់ជាតិ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
MINISTRY OF POSTS AND TELECOMMUNICATIONS

CAMBODIA RED CROSS

សូមអរគុណដល់អង្គការដៃគូរដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសៈ

terre des hommes stops child exploitation

APLE

PLAN INTERNATIONAL

ChildFund Cambodia

បោះពុម្ពដោយៈ

PLAN INTERNATIONAL

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន មានជាអាទិ៍ អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៩២ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារនិងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ អនុសញ្ញាលេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការនៅឆ្នាំ១៩៩៩ អនុសញ្ញាលេខ១៨២ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅឆ្នាំ២០០៥ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។ ទន្ទឹមនឹងនេះកម្ពុជាក៏បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ WePROTEC នៅទីក្រុងអាប៊ុយដាប៊ីឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ ផែនការអភិវឌ្ឍតាមវិស័យ រយៈពេលវែងនិងមធ្យមផ្សេងៗទៀត ទាក់ទងទៅនឹងការលើកកម្ពស់សិទ្ធិ និងកិច្ចការពារកុមារ ដើម្បីជានាឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ**គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩** សំដៅពង្រឹងប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា និងលើកកម្ពស់ការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាល "វិនិយោគលើកុមារនៅថ្ងៃនេះនឹងបង្កើតបានធនធានមនុស្សដែលមានជំនាញប្រកបដោយសក្តានុពលនាពេលអនាគត"។ តបតាមស្មារតីនេះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាពអនុវត្តគោលនយោបាយនេះដោយចែកជាបីផ្នែកគឺៈ**ផ្នែកទី១ៈ**ផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥ **ផ្នែកទី២ៈ**ផែនការអភិវឌ្ឍធនធានមនុស្សនិងថ្លៃចំណាយ និង**ផ្នែកទី៣ៈ** ផែនការត្រួតពិនិត្យនិងវាយតម្លៃ។

ផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥ ត្រូវបានរៀបចំឡើងដើម្បីតម្រង់ទិសដល់កិច្ចសម្របសម្រួល និងកិច្ចសហការរបស់អ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមមានវិស័យសាធារណៈ វិស័យឯកជនដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល អនុវត្តរួមគ្នានូវផែនការសកម្មភាពនេះដើម្បីលើកកម្ពស់សុខុមាលភាពកុមារនៅកម្ពុជា។ ផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថ្លៃចំណាយ រៀបចំឡើងដើម្បីពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈរបស់មន្រ្តីរាជការគ្រប់ប្រភេទដែលកំពុងបម្រើការងារនៅតាមក្រសួងស្ថាប័នទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបង្កើតចំនួនមន្រ្តីជំនាញតាមការចាំបាច់ក្នុងការបង្ការទប់ស្កាត់ អន្តរាគមន៍ និងការផ្តល់សេវានិងឆ្លើយតបចំពោះកុមារគ្រប់ៗរូបដែលរងគ្រោះពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាពឱ្យស្របតាមបទដ្ឋានគតិយុត្តនានាក្នុងទិសដៅអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព។ ផែនការត្រួតពិនិត្យនិងវាយតម្លៃបង្កើតឡើងដើម្បីត្រួតពិនិត្យសូចនាករសម្រាប់វិស័យកិច្ចការពារកុមារនិងជាឧបករណ៍ជាតិមួយសម្រាប់តាមដានវឌ្ឍនភាពកិច្ចការពារកុមារជាពិសេសផ្តល់នូវភស្តុតាងសុក្រឹតនិងគួរឱ្យជឿជាក់បានដែលបង្កលក្ខណៈឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្ត អាចកែសម្រួលជាបន្តបន្ទាប់នូវការផ្តល់សេវាកិច្ចការពារកុមាររបស់ខ្លួនឱ្យសម្រេចបាននូវលទ្ធផលដូចមានចែងនៅក្នុងគោលនយោបាយជាតិ និងដើម្បីបង្កើនកម្រិតវិសាលភាពដែលកម្ពុជាកំពុងខិតខំសម្រេចឱ្យបាននូវលទ្ធផលការងារផ្នែកកិច្ចការពារកុមារជាសកល និងសម្របសម្រួលឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ឥរិយាបថ និងជំនឿរបស់តួអង្គសំខាន់ៗ។

ខ្ញុំសូមកោតសរសើរចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដែលបានរួមចំណែកក្នុងការរៀបចំផែនការសម្រាប់អនុវត្តន៍គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ នេះប្រកបដោយជោគជ័យ។ ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថាអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្តផែនសកម្មភាពសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារប្រកបដោយការទទួលខុសត្រូវខ្ពស់។

ថ្ងៃច័ន្ទ ១១ រោច ខែ បឋមាសាឍ ឆ្នាំឆ្លូវ ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា គ.ស.២០២១

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**
**ប្រធាន**

**វង-សូត**

# មាតិកា


**អារម្ភកថា** ... i

**មាតិកា** ... iii

**អក្សរកាត់** ... v

**ផ្នែកទី១៖ ផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥** ... ១

**១. សេចក្តីផ្តើម** ... ១

១.១.សាវតា និងបទបទ ... **១**

១.២.គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ... ២

១.២.១.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ ... ២

១.២.២.ប្រព័ន្ធអន្តរាគមន៍ ... ៣

១.២.៣.ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា ... ៣

១.៣.ទិដ្ឋភាពរួមនៃស្ថានភាពកុមារនៅកម្ពុជា ... ៥

១.៤.ដំណើរការរៀបចំផែនការ ... ៦

**២. វឌ្ឍនភាព និងបញ្ហាប្រឈម** ... ៧

២.១.វឌ្ឍនភាព ... ៧

២.២.បញ្ហាប្រឈម ... ៨

**៣. គោលដៅយុទ្ធសាស្រ្ត ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត** ... ៩

**៤. ប្រភពហិរញ្ញប្បទាននិងចំណាយប៉ាន់ស្មាន** ... ៤១

**៥. សេចក្តីសន្និដ្ឋាន** ... ៤១

**ផ្នែកទី២៖ ផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថ្លៃចំណាយ** ... ៤២

**១. សេចក្តីផ្តើម** ... ៤២

១.១.សាវតា និងបរិបទ ... ៤២

១.២.គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ ... ៤២

**២. វឌ្ឍនភាព និងបញ្ហាប្រឈម** ... ៤៣

២.១.វឌ្ឍនភាព ... ៤៣

២.២.បញ្ហាប្រឈម ... ៤៣

**៣. យុទ្ធសាស្រ្តអភិវឌ្ឍធនធានមនុស្ស** ... ៤៥

៣.១.គោលបំណង និងវិសាលភាព ... ៤៥

៣.២.សកម្មភាពជាយុទ្ធសាស្រ្តអភិវឌ្ឍធនធានមនុស្ស ... ៤៥

៣.២.១.ការសិក្សាពីធនធានមនុស្សនៅក្នុងប្រព័ន្ធកិច្ចការពារកុមារ ... ៤៥

ក.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ ... ៤៥

ខ.ប្រព័ន្ធអន្តរាគមន៍ ... ៤៦

គ.ប្រព័ន្ធឆ្លើយតបនិងផ្ដល់សេវា ............................................................ ៤៦
៣.២.២.ការរៀបចំនិងអនុវត្តការបណ្ដុះបណ្ដាលប្រកបដោយប្រសិទ្ធភាព ............................ ៤៦
៣.២.៣.ការបង្កើនចំនួនមន្ត្រីជំនាញសម្រាប់បង្ការទប់ស្កាត់ អន្តរាគមន៍ ឆ្លើយតបនិងផ្ដល់សេវា .......... ៤៧
៣.២.៤.ការពង្រឹងនូវសកម្មភាពជួយផ្ដល់ប្រឹក្សាឬហ្វឹកហ្វឺនដល់មន្ត្រីជំនាញ ............................ ៤៩
៣.២.៥.ការរៀបចំកម្មវិធីស្ដីពីកិច្ចការពារកុមារនៅក្នុងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈសំខាន់ៗ ............. ៤៩
៣.២.៦.ការបង្កើនកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍធនធានមនុស្ស ...................................... ៥០
**៤. តម្រូវការថវិកាសម្រាប់អនុវត្តផែនការ** ........................................................ ៥៧
**៥. សេចក្ដីសន្និដ្ឋាន** ...................................................................... ៥៧
**ផ្នែកទី៣៖ ផែនការត្រួតពិនិត្យ និងវាយតម្លៃ** .................................................. ៥៨
**១. សេចក្ដីផ្ដើម** ........................................................................ ៥៨
**២. គោលបំណងនៃផែនការត្រួតពិនិត្យនិងវាយតម្លៃ** ............................................. ៥៨
**៣. យន្តការត្រួតពិនិត្យ និងវាយតម្លៃ** ........................................................ ៥៩
**៤. ក្រុមទិន្នន័យនៃសូចនាករ** ............................................................... ៥៩
**៥. តម្រូវការថវិកាសម្រាប់អនុវត្តផែនការ** ........................................................ ៦០

# អក្សរកាត់

| | |
|---|---|
| កបទ.សអ | ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ក.ព.ម. | ក្រសួងព័ត៌មាន |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ក.ធ.ស. | ក្រសួងធម្មការនិងសាសនា |
| ក.វ.វ. | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.យ.ធ. | ក្រសួងយុត្តិធម៌ |
| ក.ក.ប.វ. | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ក.ស.ភ. | ក្រសួងសុខាភិបាល |
| ក.ស.ហ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ម.ផ. | ក្រសួងមហាផ្ទៃ |
| ក.ព.ម. | ក្រសួងព័ត៌មាន |
| ស.ស.គ.ម. | គណៈមេធាវីកម្ពុជា |
| ក.ក.ជ. | ក្រុមប្រឹក្សាស្តារ អភិវឌ្ឍវិស័យកសិកម្មនិងជនបទ |
| សភពណ.កជ | សភាពាណិជ្ជកម្មកម្ពុជា |
| ក.ត.ក | ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា |
| ក.ក្រ.ក. | កាកបាទក្រហមកម្ពុជា |
| អ.រ.ប. | អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ |
| អ.ន.ប. | អគ្គស្នងការនគរបាលជាតិ |
| គ.ជ.អ. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.គ.ម. | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| ប.ន.ក. | បណ្ឌិត្យសភានគរបាលកម្ពុជា |
| ស.វ.ត. | សាលាវិជ្ជាជីវៈតុលាការ |
| ក.អ.ហ. | កងរាជអាវុធហត្ថលើផ្ទៃប្រទេស |
| រ.ថ.ជ. | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ក.ហ.គ | ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ |
| ប.ប.អ | ការបន្សាំការប្រែប្រួលអាកាសធាតុ |
| ក.ជ.ក | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| វ.ជ.ស. | វិទ្យាស្ថានជាតិស្ថិតិ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ |
| គ.ជ.ប.ជ | គណៈកម្មាធិការជាតប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| គ.រ.ប.ជ | គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី |
| គ.ខ.ប.ជ | គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត |

| | |
|---|---|
| ក.ស.ជ. | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ម.ស.អ.យ. | មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.ក.ប | ក្រុមការងារបច្ចេកទេស |
| អ.ម.រ | អង្គការមិនមែនរដ្ឋាភិបាល |

## ផ្នែកទី១៖ ផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥

## ១. សេចក្តីផ្តើម

### ១.១. សាវតា និងបរិបទ

កម្ពុជាធ្លាប់រងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរ ដោយរបបវាលពិឃាដប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានកាប់សម្លាប់ប្រជាជនជាងពីរលាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវរងការកាប់សម្លាប់ និងធ្វើទារុណកម្មគ្រប់បែបយ៉ាងបណ្តាលឱ្យកម្ពុជាបាត់បង់ធនធានមនុស្សជាច្រើន។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ទន្ទឹមនឹងការស្តារនិងអភិវឌ្ឍន៍ប្រទេសពីបាតដៃទទេ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិរបស់កុមារកម្ពុជាត្រូវបានការពារ និងលើកតម្កើងដោយចាត់ទុកកុមារជាអ្នកបន្តវេនរបស់ប្រទេសជាតិ ដូចពាក្យស្លោកថា "កុមារជាទំពាំងស្នងឫស្សី"និង"វិនិយោគលើកុមារនៅថ្ងៃនេះនឹងបង្កើតបានធនធានមនុស្សដែលមានជំនាញប្រកបដោយសក្តានុពលនាពេលអនាគត"។

បច្ចុប្បន្នរាជរដ្ឋាភិបាល បានបោះជំហានទៅមុខក្នុងការស្តារសង្គមនិងសេដ្ឋកិច្ចឡើងវិញ ដែលតម្រូវឱ្យកសាងធនធានមនុស្ស ជំនាញ និងប្រជាជនដែលមានសុខភាពល្អ។ រាជរដ្ឋាភិបាលបានវិភាជធនធានបន្ថែមទៀតដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតដែលទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលក្នុងនោះបានផ្តោតសំខាន់លើការអភិវឌ្ឍសុខុមាលភាពកុមារផងដែរ។ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ជាមធ្យមក្នុងរង្វង់ ៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយ ហើយបានប្រែក្លាយខ្លួនជាប្រទេសមួយក្នុងចំណោមប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតក្នុងពិភពលោក ព្រមទាំងបានឆ្លងកាត់ពីឋានៈប្រទេសចំណូលទាប មកជាប្រទេសចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ កន្លងទៅ។ អត្រាភាពក្រីក្រនៅកម្ពុជាបានបន្តធ្លាក់ចុះជាលំដាប់ពីជាង៥៣% ក្នុងឆ្នាំ២០០៤ មកត្រឹម១៣,៥% ក្នុងឆ្នាំ២០១៤ ហើយត្រូវបានប៉ាន់ស្មានថាស្ថិតនៅក្នុងរង្វង់១០% នាបច្ចុប្បន្ន។ វិស័យសុខាភិបាល អប់រំ និងសង្គមកិច្ច ក៏សម្រេចបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីនៅមានសេសសល់បញ្ហាប្រឈមមួយចំនួនដែលរាជរដ្ឋាភិបាលត្រូវបន្តដោះស្រាយក៏ដោយ។ ជាមួយនឹងសមិទ្ធផលដ៏ធំធេងនេះ កម្ពុជាមានមហិច្ឆតាក្នុងការក្តាប់យកមកវិញនូវមោទនភាពជាតិតាមរយៈការប្រែក្លាយខ្លួន ទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និង ជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើនជាអាទិ៍ អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៩២ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ អនុសញ្ញាលេខ១៣៨ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការនៅឆ្នាំ១៩៩៩ អនុសញ្ញាលេខ១៨២ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅឆ្នាំ២០០៥និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។ ទន្ទឹមនេះកម្ពុជាក៏បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ WePROTEC នៅទីក្រុងអាប៊ុយដាប៊ីឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ។

ក្នុងនាមជាប្រទេសហត្ថលេខី រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ និងផែនការអភិវឌ្ឍតាមវិស័យ រយៈពេលវែង និងមធ្យមផ្សេងៗទៀតទាក់ទងទៅនឹងការលើកកម្ពស់និងការការពារសិទ្ធិ

កុមារ និងជានាឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ និងបង្កើតប្រព័ន្ធដែលមានក្រសួង ស្ថាប័ន និងយន្តការកិច្ចការពារកុមារប្រទាក់ក្រឡាជាពហុវិស័យនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីបង្ការទប់ស្កាត់និងឆ្លើយតបគ្រោះមហន្តរាយ ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក ការទុកកូនចោល និងការជាប់ពន្ធនាគាររបស់ឪពុកម្តាយ ជាហេតុធ្វើឱ្យកុមារទទួលរងនូវបញ្ហាប្រឈមនានា រួមមាន កុមារបែកចេញពីគ្រួសារ ជួញដូរ រងអំពើហិង្សា ការគំរាមកំហែង ការរំលោភបំពាន ទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ទាំងការកេងប្រវ័ញ្ចគ្រប់ទម្រង់។

- **យន្តការសម្របសម្រួលកិច្ចការពារកុមារនៅថ្នាក់ជាតិមាន៖**១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ២.ក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន ៣.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ៤.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៥.គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ៦.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ៧.គណៈកម្មការការពារកុមារថ្នាក់ជាតិ ៨.គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង៩.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។
- **យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិមាន៖** ១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្ត ២.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានីខេត្ត "គ.ក.ស.ក" ៣.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ក្រុង ស្រុក ខណ្ឌ "គ.ក.ស.ក" ៤.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ "គ.ក.ន.ក" ៥.គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត ៦.គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី"គ.រ.ប.ជ"គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត "គ.ខ.ប.ជ" និង ៧.យន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ។

## ១.២.គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ

គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ[1] បានកំណត់នូវសសរស្តម្ភជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៣ ដោយផ្តោតទៅលើការបង្ការនិងទប់ស្កាត់ ការអន្តរាគម និងការផ្តល់សេវាឆ្លើយតប ជាមួយគ្នានេះដែរក៏បានកំណត់នូវសកម្មភាពជាក់លាក់សម្រាប់ក្រសួងស្ថាប័នដែលបំពេញការងារ បង្ការទប់ស្កាត់ ការអន្តរាគម ការផ្តល់សេវាឆ្លើយតប ជាពហុវិស័យទាន់ពេលវេលាចំពោះកុមារគ្រប់រូប ដោយគ្មានការរើសអើង និងត្រូវឱ្យមានភាពប្រទាក់ក្រឡានិងស៊ីចង្វាក់គ្នាចាប់ពីវិធានការបង្ការទប់ស្កាត់រហូតដល់ការឆ្លើយតបចំពោះកុមាររងគ្រោះ ឱ្យទទួលបានសុវត្ថិភាព ទាំងផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាព។ ដើម្បីផ្តល់សេវាកិច្ចការពារកុមារ និងជំរុញឱ្យមានផ្លាស់ប្តូរឥរិយាបថសង្គមចំពោះការប្រព្រឹត្តទៅលើកុមារគឺទាមទារឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានធនធានមនុស្សនិងថវិកាគ្រប់គ្រាន់។

### ១.២.១.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ

ប្រព័ន្ធអប់រំ៖ **ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធផ្សព្វផ្សាយ៖ **ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសភាពាណិជ្ជកម្មកម្ពុជា**

វិស័យសាសនានិងទំនៀមទម្លាប់ជនជាតិដើមភាគតិច៖ **ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងស្ត្រីនិងកុមារ៖ **រដ្ឋបាលថ្នាក់ក្រោមជាតិ-អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ**

ប្រព័ន្ធសុខុមាលភាពគ្រួសារនិងការចិញ្ចឹមកូនតាមបែបវិជ្ជមាន៖ **ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី**

---

[1] គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ អនុម័តដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

រូបភាពទី១.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ




### ១.២.២.ប្រព័ន្ធអន្តរាគមន៍

យន្តការតុលាការ៖ **ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**

យន្តការនគរបាលយុត្តិធម៌៖ **អគ្គស្នងការដ្ឋាននគរបាលជាតិ បណ្ឌិត្យសភានគរបាលកម្ពុជា បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងស្ត្រីនិងកុមារ៖ **រដ្ឋបាលថ្នាក់ក្រោមជាតិ-អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ**

រូបភាពទី២.ប្រព័ន្ធអន្តរាគមន៍




### ១.២.៣.ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា

ប្រព័ន្ធសុខុមាលភាពកុមារនិងគ្រួសារ៖**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ប្រព័ន្ធអប់រំ៖**ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធសុខាភិបាល៖**ក្រសួងសុខាភិបាល**

ប្រព័ន្ធគាំពារសង្គម៖**ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សភាពាណិជ្ជកម្មកម្ពុជា**

ប្រព័ន្ធរាយការណ៍៖ **អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ**

ប្រព័ន្ធទូរស័ព្ទជំនួយ៖**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

យន្តការភ្នាក់ងារផ្តល់សេវាសង្គមកិច្ច៖**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី**

យន្តការផ្តល់សេវាផ្នែកច្បាប់៖**ក្រសួងយុត្តិធម៌ និងគណៈមេធាវីកម្ពុជា**

យន្តការឆ្លើយតបគ្រោះមហន្តរាយ៖**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា**

រូបភាពទី៣.ប្រព័ន្ធផ្តល់សេវាឆ្លើយតប




ប្រព័ន្ធកិច្ចការពារកុមារ គឺជាបណ្តុំនៃវិធានបង្កើតឡើងក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការការពារកុមារពីការរំលោភបំពាននិងការកេងប្រវ័ញ្ចគ្រប់ទម្រង់។ វិធានទាំងនេះរួមមាន៖១.ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ២.ការផ្តល់ជំនួយនិងសេវា ៣.ធនធានមនុស្សនិងហិរញ្ញវត្ថុ និង៤.ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តទៅលើកុមារដែលវិធានទាំងនេះត្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសវិស័យសុខុមាលភាពសង្គម អប់រំ សុខភាព សន្តិសុខ និងយុត្តិធម៌ ក្នុងការគាំទ្រដល់ការបង្ការទប់ស្កាត់និងឆ្លើយតបទៅនឹងហានិភ័យផ្សេងៗ។ ដើម្បីសម្រេចនូវវិធានទាំងបួននេះ គោលនយោបាយជាតិបានដាក់ចេញនូវគោលដៅចំនួន៥[2] និងយុទ្ធសាស្ត្រមួយចំនួន។

រូបភាពទី៤៖ បណ្តុំនៃវិធានការកិច្ចការពារកុមារ




[2]គោលដៅទាំង៥៖(១)អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព(២)រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ (៣)អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ(៤)លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង (៥)ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង។

## ១.៣. ទិដ្ឋភាពរួមនៃស្ថានភាពកុមារនៅកម្ពុជា

កម្ពុជាជាប្រទេសដែលមានប្រជាជនវ័យក្មេងច្រើន ប្រមាណពាក់កណ្ដាលមានអាយុតិចជាង២៥ឆ្នាំ ក្នុងនោះមានអត្រាកំណើនប្រជាជនមាននិន្នាការកើនឡើងជាបន្តបន្ទាប់ប្រមាណ១៤,១%។[3] កំណើនប្រជាជនវ័យក្មេងនេះ ប្រសិនបើមានការវិនិយោគគ្រប់គ្រាន់លើធនធានមនុស្ស សុខាភិបាល និងកិច្ចការពារកុមារ នឹងបង្កើតបានជាស្នូលនៃផលលាភប្រជាសាស្ត្រ ដែលជាផលប្រយោជន៍សង្គម សេដ្ឋកិច្ច។ ការធ្លាក់ចុះនៃអត្រាលទ្ធភាពផ្ដល់កំណើតសរុប នឹងកាត់បន្ថយផលធៀបពឹងផ្អែកសេដ្ឋកិច្ចនៅរយៈពេល៣ទសវត្សបន្ទាប់ ដែលនាំមកនូវចំណូលខ្ពស់ និងចូលរួមចំណែកដល់កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)។

កត្តាគ្រោះមហន្តរាយ ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក ការទុកកូនចោល និងការជាប់ពន្ធនាគាររបស់ឪពុកម្ដាយ ជាហេតុធ្វើឱ្យកុមារទទួលរងនូវបញ្ហាប្រឈមនានា រួមមានកុមារបែកចេញពីគ្រួសារ ជួញដូរ រងអំពើហិង្សា ការគំរាមកំហែង ការរំលោភបំពាន ទាំងផ្លូវកាយ ផ្លូវចិត្តនិងផ្លូវភេទ ទាំងការកេងប្រវ័ញ្ចគ្រប់ទម្រង់។ តាមការអង្កេតនៅឆ្នាំ២០១៣ ដោយក្រសួងកិច្ចការនារី និងអង្គការយូនីសេហ្វ ស្ដីពីអំពើហិង្សាលើកុមារបានឱ្យដឹងថា កុមារម្នាក់ក្នុងចំណោមពីនាក់បានទទួលរងអំពើហិង្សាលើរាងកាយ កុមារម្នាក់ក្នុងចំណោម៤នាក់ បានទទួលរងអំពើហិង្សាលើផ្លូវចិត្ត ហើយកុមារម្នាក់ក្នុងចំណោម២០នាក់ បានទទួលរងអំពើហិង្សាលើផ្លូវភេទ។ ការសិក្សានោះក៏បានបង្ហាញដែរថា អ្នកដែលរំលោភបំពានលើកុមារ គឺភាគច្រើនជាមនុស្សដែលជិតស្និទ្ធជាមួយកុមារបំផុត ដូចជាឪពុកម្ដាយ អាណាព្យាបាល និងអ្នកថែទាំកុមារ។ យោងតាមលទ្ធផលស្រាវជ្រាវនេះបានបញ្ជាក់ថា កុមារនៅក្នុងប្រទេសកម្ពុជានៅមិនទាន់មានសុវត្ថិភាពនិងការអភិវឌ្ឍពេញលេញនៅឡើយទេ។ ដូច្នេះឪពុកម្ដាយ អាណាព្យាបាល និងអ្នកថែទាំគួរសិក្សាស្វែងយល់ពីអំពើហិង្សាលើកុមារនិងផលប៉ះពាល់លើកុមារ គ្រួសារ សង្គមជាតិ សេដ្ឋកិច្ចក្នុងគ្រួសារ ក៏ដូចសេដ្ឋកិច្ចប្រទេសជាតិដែរ។ ការយល់ដឹងអំពីផលប៉ះពាល់នេះ អាចជួយឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ បញ្ឈប់អំពើហិង្សានិងការមិនអើពើលើកុមារ។ បន្ថែមពីលើនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គប្បីទទួលបានការគាំទ្រក្នុងការការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ រួមទាំងការមិនអើពើលើកុមារដែលអាចកើតមានឡើងទាំងនៅខាងក្នុងនិងក្រៅផ្ទះ។

យោងតាមលទ្ធផលការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារនៅឆ្នាំ២០១៣របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានបង្ហាញថា ចំនួនកុមារសរុបអាយុ៥-១៧ឆ្នាំ នៅកម្ពុជាមាន៣.៩៥៦.៧៥១នាក់ នៅទូទាំងប្រទេស។ កុមារចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចមានចំនួន ៧៥៥.២៤៥នាក់ ក្នុងចំណោមកុមារជិត៤លាននាក់ អាយុ១៥-១៧ឆ្នាំ (ប្រមាណ៨១% មិនធ្វើការ និង១៩% បានទៅធ្វើការ។ កុមារ៦%ស្ថិតក្នុងការងារប្រកបដោយ គ្រោះថ្នាក់៤,៩% នៅក្នុងទម្រង់ផ្សេងៗនៃពលកម្មកុមារ និង៨,២% ធ្វើការក្នុងលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព។ គិតមកត្រឹមឆ្នាំ២០១២ ពលកម្មកុមារមានត្រឹម៤២៩.៣៨០នាក់ រីឯទម្រង់ធ្ងន់ធ្ងរបំផុត ឬកុមារធ្វើពលកម្មប្រកបដោយគ្រោះថ្នាក់មាន ២៣៦.៤៩៨នាក់ និងកុមារធ្វើការប្រកប ដោយសុវត្ថិភាពមាន ៣២៥.៨៦៥នាក់។[4]

យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមឆ្នាំ២០១៧ បានបង្ហាញថា កុមារចូលរួមសកម្មភាពសេដ្ឋកិច្ច៧៣ម៉ឺននាក់ ស្មើ១៧% នៃចំនួនកុមារជិត៤,៣លាននាក់ ពលកម្មកុមារអាចថយចុះមកត្រឹមរង្វង់៣០ម៉ឺននាក់ នៅក្នុងចំណោមកុមារជិត៤៤ម៉ឺននាក់ដែលមិនបានចូលរៀន។[5] អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រនៅកម្ពុជាឆ្នាំ២០១៣ ផ្អែកលើនិយម

[3] ការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ ឆ្នាំ២០១៣ (រយៈពេល១១ឆ្នាំ រវាងឆ្នាំ២០០៨ និងឆ្នាំ២០១៩)

[4] ប្រភព៖ ការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ ឆ្នាំ២០១៣

[5] ប្រភព៖ ការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ ឆ្នាំ២០១៧

ន័យទូទៅបង្ហាញថា សមាមាត្រនៃ ពលកម្មកុមារសរុបមានប្រមាណ៩,៩% ដោយមានក្មេងប្រុសចំនួន៩,៣%និងក្មេងស្រីចំនួន១០,៧% គិតជាចំនួនមានប្រមាណ៣៥៦ ៩៣២ ពលកម្មកុមារក្នុងកម្លាំងពលកម្ម។ ប៉ុន្តែ អង្កេតដែលធ្វើឡើងដោយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនិងអង្គការពលកម្មពិភពលោកបង្ហាញថា កុមារចំនួន១១% (ស្មើនឹង៤២៩ ៣៨០នាក់) ជាពលកម្មកុមារ។ តួលេខពីប្រភពទាំងពីរនេះមានគម្លាតគ្នាប្រមាណ ៧២ ៤៤៨នាក់ ដោយសារតែការប្រើប្រាស់វិធីសាស្ត្រខុសគ្នា។

យោងតាមរបាយការណ៍ស្តីពីការកំណត់ទីតាំង កន្លែងថែទាំកុមារក្នុងរាជធានី ខេត្តទាំង២៥ នៃកម្ពុជានៅ ឆ្នាំ២០១៧ មានកន្លែងថែទាំកុមារចំនួន៦៣៩កន្លែង ដែលមានកុមារនិងយុវជនចំនួន៣៥៣៧៤នាក់ ក្នុងនោះកុមារដែលមានអាយុពី០ដល់១៧ឆ្នាំ ចំនួន២៦ ១៨៧នាក់ (ស្រី១២ ៥២៦នាក់)។ យោងតាមរបាយការណ៍នេះ មណ្ឌលថែទាំកុមារមានចំនួន៤០៦កន្លែង មានកុមារសរុបចំនួន១៦ ៥៧៩នាក់ ក្នុងនោះមណ្ឌលរដ្ឋមានចំនួន២២មណ្ឌល មានកុមារនិងយុវជនចំនួន១ ៦០១នាក់(ស្រី៧២៤នាក់)។ កន្លែងថែទាំកុមារនៅតាមសហគមន៍ រួមមាន ផ្ទះស្នាក់នៅបណ្តោះអាសន្ន២៥កន្លែង មានកុមារចំនួន៦២៨នាក់ (ស្រី៣៤៨នាក់) ផ្ទះស្នាក់នៅជាក្រុម ៧១កន្លែង មានកុមារ១៥៩២នាក់(ស្រី៨២០នាក់) ក្រៅពីនោះកុមារមួយចំនួនកំពុងស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន ទីវត្តអារាម និងទីកន្លែងសាសនា ១៣៧កន្លែង មានកុមារចំនួន៧ ៣៨៨នាក់ (ស្រី៣ ៥៨២នាក់)។ កុមារទាំងនេះសុទ្ធតែទទួលបាននូវសេវាស្នាក់នៅ អប់រំ ចិញ្ចឹមបីបាច់ថែរក្សាបង្កលក្ខណៈឱ្យរៀនសូត្រចំណេះដឹងទូទៅ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បង្រួបបង្រួមគ្រួសារ និងធ្វើសមាហរណកម្មទៅរស់នៅក្នុងសហគមន៍វិញ។ ទោះបីជាស្ថានភាពសុខុមាលភាពរបស់កុមារមានភាពល្អប្រសើរយ៉ាងណាក៏ដោយ ក៏នៅមិនទាន់បានឆ្លើយតបទៅនឹងកម្រិតជីវភាពរស់នៅ និងតម្រូវការជាក់ស្តែងរបស់កុមាររងគ្រោះនិងងាយរងគ្រោះ និងគ្រួសារនៅតាមសហគមន៍នៅឡើយ។ កុមាររស់នៅក្នុងមណ្ឌល និងនៅតាមសហគមន៍មួយចំនួននៅតែប្រឈមនឹងបញ្ហាមួយចំនួនជាអាទិ៍ការរំលោភបំពាន ការកេងប្រវ័ញ្ចគ្រប់ទម្រង់ អំពើហិង្សា សុខភាព អាហារូបត្ថម្ភ ការអប់រំ សង្គម អារម្មណ៍ផ្លូវចិត្ត និងការពង្រឹងផ្នែកសេដ្ឋកិច្ច និងជីវភាពរស់នៅប្រចាំថ្ងៃដែលតម្រូវឱ្យមានការខិតខំបន្ថែមទៀតដើម្បីឧត្តមប្រយោជន៍របស់កុមារ។

## ១.៤. ដំណើរការរៀបចំផែនការ

ដំណើរការរៀបចំផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥ ផែនការធនធានមនុស្សនិងថវិកានិងផែនការត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ ២០១៩-២០២៩ បានចាប់ផ្តើមដំណើរការពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ២០២០[6] ដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដោយមានជំនួយពីទីប្រឹក្សាបច្ចេកទេសក្រោមការឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ ការរៀបចំផែនការទាំងបីនេះគឺយោងលើគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ និងការប្រមូលទិន្នន័យ និងធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងឯកសារពាក់ព័ន្ធនានា។

សេចក្តីព្រាងសូន្យនៃផែនការ(១.ផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥ ២.ផែនការធនធានមនុស្សនិងថវិកា និង៣.ផែនការត្រួតពិនិត្យនិងវាយតម្លៃ) សម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ ត្រូវបានកែសម្រួលដោយក្រុមការងារនៃអគ្គលេខាធិការដ្ឋាន ក.ជ.ក ដើម្បីរៀបចំសេចក្តីព្រាងទី១ ដាក់ជូនកិច្ចប្រជុំក្រុមការងារបច្ចេកទេស នៃគណៈកម្មាការការពារកុមារថ្នាក់ជាតិនៅថ្ងៃទី២៥ -២៧ ខែសីហា ឆ្នាំ២០២០ នៅខេត្តព្រះសីហនុ ក្នុងគោលបំណងប្រមូលធាតុចូលសម្រាប់រៀបចំសេចក្តីព្រាងទី២។ សេចក្តីព្រាងទី២

[6] សកម្មភាពក្រុមការងារបច្ចេកទេស ក.ជ.ក ត្រូវបានពន្យាពេលរហូតដល់ខែសីហា ឆ្នាំ២០២១ ដោយសារបញ្ហាជំងឺរាតត្បាតកូវីត-១៩

ត្រូវបានពិនិត្យកែសម្រួល និងផ្តល់ជាតុចូលពីក្រុមការងារបច្ចេកទេស នៃគណៈកម្មាការការពារកុមារថ្នាក់ជាតិ នៅកិច្ចប្រជុំថ្ងៃទី២៧-២៨ ខែធ្នូ ឆ្នាំ២០២០ នៅខេត្តពោធិសាត់ និងអង្គសិក្ខាសាលាពិគ្រោះយោបល់ជាមួយតំណាងកុមារ និងយុវជនថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ នៅរាជធានីភ្នំពេញសម្រាប់បញ្ចប់សេចក្តីព្រាងទី២។ សេចក្តីព្រាងទី២ ត្រូវបានដាក់ជូនអង្គសិក្ខាសាលាអន្តរក្រសួងថ្ងៃទី១៧ ខែមិថុនា ២០២១ នៅរាជធានីភ្នំពេញដើម្បីប្រមូលទិន្នន័យនិងធាតុចូលបន្ថែមសម្រាប់រៀបចំសេចក្តីព្រាងទី៣ ដាក់ជូនក្រុមការងារបច្ចេកទេសនៃគណៈកម្មាការការពារកុមារថ្នាក់ជាតិនៅកិច្ចប្រជុំនៅថ្ងៃទី២២-២៤ ខែមិថុនា ឆ្នាំ២០២១ នៅខេត្តព្រះវិហារ ដើម្បីពិនិត្យនិងកែសម្រួលចុងក្រោយមុនដាក់ជូនប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារពិនិត្យសម្រេច និងផ្សព្វផ្សាយអនុវត្ត។

## ២. វឌ្ឍនភាព និងបញ្ហាប្រឈម

### ២.១. វឌ្ឍនភាព

កម្ពុជាសម្រេចបាននូវវឌ្ឍនភាពក្នុងការអនុវត្តប្រព័ន្ធកិច្ចការពារកុមារជាលក្ខណៈពហុវិស័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចជា (១)ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ (២)វិភាជថវិកាដើម្បីទ្រទ្រង់ការអនុវត្តគោលនយោបាយ (៣)រៀបចំនិងអនុវត្តក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ (៤)កសាងសមត្ថភាពនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ ដើម្បីលើកកម្ពស់សុខុមាលភាពកុមារ។

**ជំរុញនិងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារៈ** កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា រដ្ឋធានាការពារសិទ្ធិរបស់កុមារដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច និងកាមគុណលើកុមារ។ ជាមួយគ្នានេះ ការយកចិត្តទុកដាក់ការគាំពារប្រឆាំងនឹងការងារទាំងឡាយដែលធ្វើឱ្យខូចដល់ការអប់រំនិងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាពឬសុខុមាលភាពរបស់កុមារ។ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារ កម្ពុជាបានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិនិងពិធីសារបន្ថែមដែលពាក់ព័ន្ធនឹងកុមារជាច្រើនទៀត។ ទន្ទឹមនេះកម្ពុជាក៏បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារនៅខែកញ្ញា ឆ្នាំ២០១៩ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ WePROTEC នៅទីក្រុងអាប៊ុយដាប៊ីឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ។

**វិភាជថវិកាដើម្បីទ្រទ្រង់ការអនុវត្តគោលនយោបាយៈ** ដោយមានកំណើនសេដ្ឋកិច្ចកើនឡើងរៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យសង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀតក្នុងគោលដៅធ្វើឱ្យសុខុមាលភាពប្រជាជនកាន់តែ ប្រសើរឡើង ជាពិសេសចំពោះកុមារ និងសម្រេចបានគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ប្រជាជនកម្ពុជា ជាពិសេសកុមារ បាននិងកំពុងទទួលផ្លែផ្កាពីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ច យ៉ាងឆាប់រហ័សក្នុងអត្រាមធ្យមប្រមាណ៧,៧% នាអំឡុងពេលពីទសវត្សកន្លងមកនេះ។ អត្រាភាពក្រីក្រនៅកម្ពុជាបានបន្តធ្លាក់ចុះជាលំដាប់ពីជាង ៥៣% ក្នុងឆ្នាំ២០០៤ មកត្រឹម ១៣,៥% ក្នុងឆ្នាំ២០១៤ ហើយត្រូវបានប៉ាន់ស្មានថា ស្ថិតនៅក្នុងរង្វង់១០% នាបច្ចុប្បន្ន។ លើសពីនេះទៀត ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចក៏ត្រូវបានបែងចែកក្នុងលក្ខណៈកាន់តែមានសមធម៌ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃមេគុណវិសមភាពនៃការប្រើប្រាស់០,៤១ នៅឆ្នាំ ២០០៧ មកនៅត្រឹម០,២៩ នៅឆ្នាំ២០១២ ជាមួយនឹងការរំពឹងថាតួលេខនេះនឹងបន្តថយចុះថែមទៀតនៅឆ្នាំខាងមុខ បើសិនមិនមានផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច។ ទន្ទឹមនេះរាជរដ្ឋា

ភិបាលបានរៀបចំនិងអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ[7] កម្មិធីផ្តល់របបគោលនយោបាយចំពោះជនមានពិការភាពក្រីក្រ[8] កម្មវិធីផ្តល់របបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ[9] និងកម្មវិធីមួយចំនួនទៀតសម្រាប់លើកកម្ពស់សុខុមាលភាព និងកិច្ចការពារកុមារ។ល។

**ការរៀបចំ និងអនុវត្តក្របខ័ណ្ឌគតិយុតតពាក់ព័ន្ធនឹងកិច្ចការពារកុមារ៖** ដោយយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះសិទ្ធិកុមារ កម្ពុជាបានអនុម័តច្បាប់មានដូចជាច្បាប់ស្តីពីសុំកូនអន្តរប្រទេស ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការងារ ។ល។ ព្រមទាំងបានបង្កើតគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម គោលនយោបាយជាតិស្តីពីគាំពារ និងអភិវឌ្ឍន៍កុមារតូច គោលនយោបាយជាតិស្តីពីសុខភាពសិក្សា គោលនយោបាយស្តីពីការអប់រំបរិយាបន្ន គោលនយោបាយវត្តសង្គហកុមារ គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០ យុទ្ធសាស្រ្តចតុកោណ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងលិខិតបទដ្ឋាគតិយុត្តមួយចំនួនទៀតដើម្បីគាំទ្រដល់ការផ្តល់កិច្ចការពារកុមារ។ល។

**កសាងសមត្ថភាពនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ៖** រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការផ្តល់សេវាការពារកុមារ។ សេវាការពារកុមារនៅក្នុងប្រទេសកម្ពុជាត្រូវបានពង្រឹងកាន់តែប្រសើរឡើងតាមរយៈគម្រោងនិងកម្មវិធីកិច្ចសហប្រតិបត្តិការនានារបស់អង្គការសង្គមស៊ីវិល។ ក្នុងរយៈពេល២ទសវត្សកន្លងទៅនេះ ទីភ្នាក់ងារជាតិនិងអន្តរជាតិដែលធ្វើការងារពាក់ព័ន្ធនឹងកុមារ បានធ្វើឱ្យសម្រេចនូវសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការតស៊ូមតិដើម្បីកុមារទទួលបានសិទ្ធិការពារ ជួយកសាងសមត្ថភាពបុគ្គលិកសង្គមនៅគ្រប់កម្រិត និងផ្តល់សេវាដោយផ្ទាល់ដល់កុមារ គ្រួសារនិងសហគមន៍ងាយរងគ្រោះ។ ទន្ទឹមនេះកម្ពុជាក៏បានបង្កើតយន្តការជាច្រើនប្រទាក់ក្រឡាជាពហុវិស័យទាក់ទងនឹងកិច្ចការពារកុមារដើម្បីធានាការអនុវត្តពេញលេញនូវអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## ២.២.បញ្ហាប្រឈម

ទោះបីជារាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមតាមរយៈការដាក់ចេញនូវច្បាប់ គោលនយោបាយ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានា និងដោយមានការចូលរួមចំណែកពីអ្នកពាក់ព័ន្ធក្នុងការជួយដល់កុមារយ៉ាងណាក៏ដោយ ក៏នៅមានកុមារមួយចំនួនកំពុងប្រឈមនឹងបញ្ហាជាច្រើនដូចជាកុមារត្រូវបានគេជួញដូរ រំលោភបំពាន កេងប្រវ័ញ្ចផ្សេងៗ កុមារដែលត្រូវគេបោះបង់ចោល ការបោះបង់ការសិក្សា កង្វះអាហារូបត្ថម្ភ សុខភាព អនាម័យ ទឹកស្អាត អំពើហិង្សា ពលកម្មកុមារ កុមារធ្វើទេសន្តប្រវេសន៍តាមឪពុកម្តាយ កុមារ ត្រូវឪពុកម្តាយធ្វើទេសន្តប្រវេសន៍ កុមារញៀនសារធាតុញៀន កុមារគ្មានទីជម្រក កុមារពិការ កុមារទំនាស់នឹងច្បាប់ កុមារឬអ្នកអាណាព្យាបាលមានជំងឺរ៉ាំរ៉ៃ។ល។ ជាគោលការណ៍ការទុកដាក់កុមារក្នុងមណ្ឌលថែទាំជាជម្រើសចុងក្រោយ និងជាបណ្តោះអាសន្ន ក៏ប៉ុន្តែតាមស្ថានភាពជាក់ស្តែង កុមាររងគ្រោះត្រូវបានគេយកទៅដាក់នៅក្នុងមណ្ឌលថែទាំមានការកើនឡើង។

---

[7] អនុក្រឹត្យ ២៤៥ អនក្រ.បក ថ្ងៃទី៣១ ធ្នូ ២០១៩ ស្តីពីការអនុវត្តកម្មិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

[8] អនុក្រឹត្យ ១៣៧ អនក្រ.បក ថ្ងៃទី២៨ មិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍

[9] អនុក្រឹត្យ ១១៦ អនក្រ.បក ថ្ងៃទី២៦ តុលា ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអនុក្រឹត្យ ៩០ អនក្រ.បក ថ្ងៃទី១៣ កក្កដា ២០១៥ ស្តីពីការកែសម្រួល មាត្រា៧នៃអនុក្រឹត្យ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ តុលា ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ។

កង្វះការរៀបចំនិងការទទួលបានសេវាទប់ស្កាត់សម្រាប់កុមាររងគ្រោះមកពីអំពើហិង្សា ការរំលោភបំពាន ឬការកេងប្រវ័ញ្ចគ្រប់ទម្រង់ ការមិនអើពើ និងការធ្វើអាជីវកម្ម ត្រូវបានផ្តល់ដោយអ្នកពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ ដែលជាបញ្ហាប្រឈមដ៏ធំដល់ដំណើរការនៃការអនុវត្តកិច្ចការពារកុមារដែលមានលក្ខណៈជាប្រព័ន្ធ។ ជាការពិតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) និងអង្គការសង្គមស៊ីវិលមួយចំនួនបានត្រឹមតែអនុវត្តវិធានការផ្លូវការ ដែលរួមមានការបញ្ជូនទៅមណ្ឌលសុខភាព ការរាយការណ៍អំពីករណី និងការដោះស្រាយសម្រុះសម្រួលជាមួយជនល្មើសនិងកុមាររងគ្រោះត្រឹមតែថ្នាក់មូលដ្ឋានប៉ុណ្ណោះ។ ទន្ទឹមនេះ យុទ្ធនាការនៃការអប់រំផ្សព្វផ្សាយ ការទប់ស្កាត់ ការផ្តល់ប្រឹក្សាយោបល់ទាំងផ្នែកច្បាប់និងសង្គម ការគាំទ្រ និងការថែទាំកុមារនៅក្នុងគ្រួសារ និងក្នុងសហគមន៍នៅមានកម្រិតនិងមិនទាន់ដោះស្រាយបានចំគោលដៅនៅឡើយ។

បញ្ហាកុមាររងគ្រោះតែងតែកើតមានឡើងស្ទើរគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ជាពិសេសនៅតំបន់ដាច់ស្រយាល ដែលបញ្ហានេះបណ្តាលមកពីកង្វះព័ត៌មាន ចំណេះដឹង ការអប់រំ ទំនាក់ទំនង និងការផ្លាស់ប្តូរឥរិយាបថ ក្នុងចំណោមប្រជាជនទូទៅនិងអាជ្ញាធរមូលដ្ឋាន។ ក្នុងការបំពេញតួនាទីភារកិច្ចជាពហុវិស័យរបស់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីព្រមទាំងអ្នកពាក់ព័ន្ធបាន និងកំពុងប្រឈមបញ្ហាជាច្រើនដូចជាអាណត្តិភាពនៃតួនាទីភារកិច្ចនិងការទទួលខុសត្រូវកង្វះធនធាន ខ្វះបទពិសោធន៍ និងសមត្ថភាពបច្ចេកទេសសម្របសម្រួលដោះស្រាយបញ្ហាកិច្ចការពារកុមារជាពិសេសវិធីសាស្ត្រក្នុងការបង្ការទប់ស្កាត់ អន្តរាគមន៍ និងផ្តល់សេវាឆ្លើយតប។

## ៣. គោលដៅយុទ្ធសាស្ត្រ ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ដោយបានកំណត់គោលដៅចំនួន៥មាន៖១.អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព ២.រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ ៣.អភិវឌ្ឍន៍ធនធានមនុស្សក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ ៤.លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង ៥.ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង និងបានកំណត់យុទ្ធសាស្ត្រមួយចំនួនដើម្បីសម្រេចនូវចក្ខុវិស័យ និងគោលបំណងនៃគោលនយោបាយជាតិ។

អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តរយៈពេល៥ ឆ្នាំ២០២១-២០២៥ ដោយកំណត់គោលដៅយុទ្ធសាស្ត្រជាអាទិភាពចំនួន៤មាន៖(១)អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព (២)រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ (៣)លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង[10] និង (៤)ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង[11]។

[10] គោលដៅទី៤៖លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩។

[11] គោលដៅទី៥៖ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែងកន្លែង នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩។

**គោលដៅយុទ្ធសាស្ត្រទី១៖** **អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព**[12]

**គោលបំណង៖** ដើម្បីពិនិត្យខ្លឹមសារខ្វះចន្លោះនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារសម្រាប់ជាធាតុចូលក្នុងការបង្កើតច្បាប់ស្តីពីកិច្ចការពារកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានប្រសិទ្ធភាព។

**លទ្ធផលរំពឹងទុក៖** ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារត្រូវបានអភិវឌ្ឍមានខ្លឹមសារគ្រប់ជ្រុងជ្រោយដែលធានាបាននូវឧត្តមប្រយោជន៍ និងសិទ្ធិជាមូលដ្ឋានរបស់កុមារ។

## សូចនាករ និងសកម្មភាពអនុវត្ត

| | សរសរស្តម្ភ | សូចនាករលទ្ធផល | | សកម្មភាពអនុវត្ត | តម្រូវការថវិកា | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| ១.១ | **សរសរស្តម្ភទី១៖** ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ | (១)ច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានបង្កើតឡើងមានខ្លឹមសារគ្រប់ជ្រុងជ្រោយ | ១.១.១ | បង្កើតច្បាប់ស្តីពីកិច្ចការពារកុមារគ្រប់ជ្រុងជ្រោយដោយបញ្ចូលនូវខ្លឹមសារខ្វះចន្លោះនៅក្នុងច្បាប់ពាក់ព័ន្ធនានា[13] | ៧៥,០០០ | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |
| | | (២)លិខិតបទដ្ឋានគតិយុត្តអនុវត្តច្បាប់ស្តីពីកិច្ចការពារកុមាត្រូវបានបង្កើតឡើង | ១.១.២ | រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីអនុវត្តពាក់ព័ន្ធនានាដើម្បីអនុវត្តច្បាប់ស្តីពីកិច្ចការពារកុមារ | ៥៨,០០០ | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |
| | | (៣)មាត្រាច្បាប់មួយចំនួនដែលខ្វះចន្លោះពាក់ព័ន្ធកិច្ចការពារកុមារត្រូវបានពិនិត្យនិងធ្វើវិសោធនកម្ម | ១.១.៣ | ពិនិត្យនិងធ្វើវិសោធនកម្មមាត្រាច្បាប់មួយចំនួនដែលមានការខ្វះចន្លោះពាក់ព័ន្ធកិច្ចការពារកុមារ និងបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំ | ៧៥,០០០ | x | x | x | x | x | ក.យ.ជ<br>ក.ម.ផ | រ.ថ.ជ |
| | | (៤)ផែនការយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គមត្រូវបានបង្កើតឡើងនិងអនុវត្ត | ១.១.៤ | រៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គម និងផ្សព្វផ្សាយអនុវត្ត | ៧៥,០០០ | x | x | x | | | ស.អ.យ | រ.ថ.ជ |
| | | (៥)ចំនួនកុមារកំព្រាដែលទទួលបានការសុំកូនអន្តរប្រទេស | ១.១.៥ | ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា | ៥០,០០០ | x | x | x | x | x | ស.អ.យ<br>ក.អ.យ.ក | រ.ថ.ជ |
| | | (៦)ចំនួនអនីតជនទំនាស់នឹងច្បាប់ដែលទទួលបានសេវាស្តារនីតិសម្បទា | ១.១.៦ | ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា | ៥០,០០០ | x | x | x | x | x | ស.អ.យ<br>ក.យ.ជ | រ.ថ.ជ |

---

[12] គោលដៅទី៣.២.១៖អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាពនៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩

[13] ក្រមរដ្ឋប្បវេណី ច្បាប់អប់រំ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ក្រមព្រហ្មទណ្ឌ ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងច្បាប់ស្តីពីឧក្រិដ្ឋកម្មព័ត៌មានវិទ្យា ច្បាប់ការងារ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត។

| សរសស្តម្ភ | សូចនាករលទ្ធផល | | សកម្មភាពអនុវត្ត | តម្រូវការថវិកា | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| | (៧)ចំនួនកុមារពិការដែលទទួលបានកិច្ចការពារ និងសេវាថែទាំសមស្រប | ១.១.៧ | ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលពាក់ព័ន្ធនឹងកុមារពិការ | ៦០,000 | x | x | x | x | x | ក.ស.ជ | រ.ថ.ជ |
| | (៨)អ្នកពាក់ព័ន្ធទទួលបានការយល់ដឹងអំពីនីតិវិធីអុនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ | ១.១.៨ | ផ្សព្វផ្សាយប្រកាសស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ | ៦០,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | (៩)ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមត្រូវបានអនុវត្តដោយស្ថាប័នពាក់ព័ន្ធ | ១.១.៩ | ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ២០២១-២០២៥ | ៥០,000 | x | x | x | x | x | ស.អ.យ<br>ក.ម.ផ | រ.ថ.ជ |
| ១១.២ **សរសស្តម្ភទី២៖** ប្រព័ន្ធអន្តរាគមន៍ | (១)នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសឆ្នាំ២០១១ត្រូវបានធ្វើបច្ចុប្បន្នភាព | ១.២.១ | ពិនិត្យនិងកែសម្រួលនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសឆ្នាំ២០១១ឱ្យមានសង្គតិភាពជាមួយនឹងអនុក្រឹត្យលេខ៣៤[14] និង ១៨២[15], ១៨៣[16] និង១៨៤[17] | ៧៥,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | (២)នីតិវិធី មានលក្ខណៈកុមារមេត្រីសម្រាប់ដោះស្រាយករណីកុមារត្រូវបានរៀបចំបង្កើតឡើង | ១.២.២ | រៀបចំនីតិវិធីដែលមានលក្ខណៈកុមារមេត្រីសម្រាប់ដោះស្រាយករណី និងរាយការណ៍ករណីអំពើហិង្សាលើកុមារសម្រាប់ស្ថាប័នសេវាសង្គម និងអ្នកផ្តល់សេវាសង្គមរួមមាន៖(ក)ការបញ្ជូនទៅមន្ត្រីគាំពារកុមារ-នគរបាលនិងយន្តការឆ្លើយតប(ខ)តាមដាននិងគាំទ្រ(គ)ចងក្រងជាឯកសារ និងតាមដានករណីដែលបានរាយការណ៍ | ៥៨,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |

[14] អនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "គ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត" ប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងរដ្ឋបាល

ស្រុក ប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងរដ្ឋបាលឃុំ

[15] អនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

[16] អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

[17] អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

| សរសរស្តម្ភ | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| | (៣)លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារផ្នែកសំណង់ ឡឥដ្ឋ និងកសិឧស្សាហកម្ម ត្រូវបានបង្កើត | ១.២.៣ | បង្កើតលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារផ្នែកសំណង់ ឡឥដ្ឋ និងកសិឧស្សាហកម្ម | ៧៥,000 | x | x | x | x | x | ក.ក.ប.វ | វ.ថ.ជ |
| | (៤)កុមារទទួលបានកិច្ចការពារពីការប្រើប្រាស់ពលកម្មផ្នែកសំណង់ ឡឥដ្ឋ កសិឧស្សាហកម្ម និងការងារតាមផ្ទះ | ១.២.៤ | ជំរុញការអនុវត្តប្រកាសស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ[18] និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារផ្នែកសំណង់ ឡឥដ្ឋ និងកសិឧស្សាហកម្ម | ៨៥,000 | x | x | x | x | x | ក.ក.ប.វ | វ.ថ.ជ |
| | (៥)បង្កើតគោលការណ៍សម្រាប់ការអនុវត្តផែនការបង្វែរត្រូវបានបង្កើតឡើង | ១.២.៥ | រៀបចំបង្កើតគោលការណ៍សម្រាប់ការអនុវត្តផែនការបង្វែរ និងរចនាសម្ព័ន្ធភ្នាក់ងារសង្គមកិច្ចពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន | ៥៥,000 | x | x | x | x | x | ស.អ.យ | វ.ថ.ជ |
| | (៦)ចំនួនកុមារទទួលបានការពារពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ | ១.២.៦ | ជំរុញការអនុវត្តច្បាប់ស្តីពីការងារដោយផ្តោតលើការដាក់កំហិត ការដាក់ពិន័យ និងការដាក់ទោសទណ្ឌទៅលើជនល្មើសដែលបំពានលក្ខខណ្ឌការងារនិងពលកម្មកុមារ | ៥០,000 | x | x | x | x | x | ក.ក.ប.វ | វ.ថ.ជ |
| | (៧)ភាគរយនៃកុមាររងគ្រោះនិងងាយរងគ្រោះទទួលបានសេវាកិច្ចការពារ | ១.២.៧ | ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា | ៥៦,000 | x | x | x | x | x | ក.ជ.ក | វ.ថ.ជ |
| | (៨)ចំនួនកុមាររងគ្រោះនិងងាយរងគ្រោះទទួលបានសេវាថែទាំជំនួយប្រកបដោយគុណភាព | ១.២.៨ | ជំរុញការអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួយចំពោះកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា | ៥៥,000 | x | x | x | x | x | ស.អ.យ | វ.ថ.ជ |
| | (៩)ភាគរយកុមារទទួលបានសេវាសុខាភិបាលពីគោលនយោបាយជាតិស្តីពីសុខភាពសិក្សា | ១.២.៩ | ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីសុខភាពសិក្សាឆ្នាំ២០១៩ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ៥៥,000 | x | x | x | x | x | ក.អ.យ.ក | វ.ថ.ជ |

[18] ប្រកាសលេខ ២៣៥ បក/ប្រ.ក.ម.ព ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ

| សរសរស្តម្ភ | | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| | | (១០)ភាគរយកុមារ(នេន)នៅតាមវត្តអារាមទទួលបានសេវាកិច្ចការពារ | ១.២.១០ | ជំរុញការអនុវត្តគោលនយោបាយវត្តសង្គហកុមារ[19] និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា | ៥៦,000 | x | x | x | x | x | ក.ធ.ស | រ.ថ.ជ |
| | | (១១)កិច្ចព្រមព្រាងបញ្ជូននិងទទួលកុមាររងគ្រោះត្រូវបានរៀបចំបង្កើតឡើង | ១.១.១១ | រៀបចំកិច្ចព្រមព្រៀងស្តីពីការបញ្ជូន និងទទួលកុមាររងគ្រោះជាមួយបណ្តាប្រទេស ស្ថានទូតនិងស្ថានកុងស៊ុលពាក់ព័ន្ធនានា | ៥0,000 | x | x | x | x | x | កបទ.សអ | រ.ថ.ជ |
| ១.៣ | **សរសរស្តម្ភទី៣៖** ប្រព័ន្ធឆ្លើយតប និងផ្តល់សេវា | (១)គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យស្របតាមស្ថានភាពជាក់ស្តែង | ១.៣.១ | ពិនិត្យ និងកែសម្រួលគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ២០០៦ឱ្យមានសង្គតិភាពនឹងគោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ អង្គការសហប្រជាជាតិ[20] | ៦៥,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | (២)អ្នកពាក់ព័ន្ធមានការយល់ដឹងនិងចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាព | ១.៣.២ | រៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសមាហរណកម្ម ការបង្វែ និងបិតមណ្ឌលថែទាំកុមារ និងផ្សព្វផ្សាយ | ៦៥,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | (៣)បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមាត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យស្របតាមគោលការណ៍ណែនាំស្តីពីការថែទាំជំនួសរបស់អង្គការសហប្រជាជាតិ(UN) | ១.៣.៣ | ពិនិត្យនិងកែសម្រួលបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌលឆ្នាំ២០០៦ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ឆ្នាំ២០០៨ | ៥0,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | (៤)លិខិតបទដ្ឋានដើម្បីដំណើរការមណ្ឌលយុវនីតិសម្បទាត្រូវបានបង្កើត | ១.៣.៤ | រៀបចំលិខិតបទដ្ឋាន[21]ដើម្បីដំណើរការមណ្ឌលយុវនីតិសម្បទា[22]ដោយបញ្ចូលការផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំចំណេះទូទៅដល់អនីតិជនទំនាស់នឹងច្បាប់នៅក្នុងមណ្ឌលយុវនីតិសម្បទា | ៧៥,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |

[19] គោលនយោបាយវត្តសង្គហកុមារ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០

[20].United Nation 65th plenary meeting 18 December 2009 adopted the guideline for Alternative care for children

[21] មាត្រា ៧៧ ៧៨ ៨២ ៨៣ និង៨៨ បានចែងពីបែបបទ និងនីតិវិធីនៃមណ្ឌលយុវនីតិសម្បទាកំណត់ដោយអន្តរប្រកាសរវាងក្រសួងសង្គមកិច្ចអតីយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ

[22] យោងមាត្រា ៧៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទាចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។

| សរសរស្តម្ភ | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| | (៦)កុមារចំណាកស្រុកនិងកុមារកើតនៅតាមពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែទទួលបានសំបុត្រកំណើត | ៣.៧.៦ | ជំរុញការផ្តល់សំបុត្រកំណើតដល់កុមារដែលធ្វើចំណាកស្រុកតាមឪពុកម្តាយ និងកុមារកើតនៅតាមពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ | ៦៨,០០០ | x | x | x | x | x | ក.យ.ធ<br>ស.ស.គ.ម | រ.ថ.ជ |
| | (៧)ភ្នាក់ងារសង្គមកិច្ចទទួលបានការពង្រឹងសមត្ថភាពអនុវត្តផែនការបង្វែរ | ៣.៧.៧ | ពង្រឹងសមត្ថភាពភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរកុមារប្រព្រឹត្តបទល្មើសនឹងច្បាប់[39] | ៥៥,០០០ | x | x | x | x | x | ក.យ.ធ<br>ស.ស.គ.ម | រ.ថ.ជ |
| ៣.៨ **យន្តការឆ្លើយតបគ្រោះមហន្តរាយៈ** កាត់បន្ថយការរងគ្រោះដោយគ្រោះមហន្តរាយនានាដល់កុមារា និងកុមារីនៅក្នុងសហគមន៍ | (១)ផែនការ DRR/CCA ត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីអប់រំនៅតាមសាលារៀនក្នុងសហគមន៍ | ៣.៨.១ | បញ្ជ្រាបផែនការ DRR[40]/CCA[41] តាមរយៈកម្មវិធីអប់រំនៅតាមសាលារៀនក្នុងសហគមន៍ | ៥៥,០០០ | x | x | x | x | x | គ.គ.ម.<br>ក.ក្រ.ក | រ.ថ.ជ |
| | (២)ផែនការ DRR/CCA ត្រូវបានបញ្ជ្រាបទៅក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគឃុំ សង្កាត់ | ៣.៨.២ | បញ្ជ្រាបផែនការ DRR/CCA ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ | ៥២,០០០ | x | x | x | x | x | គ.គ.ម | រ.ថ.ជ |
| | (៣)កុមារនិងក្រុមគ្រួសារទទួលបានសេវាសង្គ្រោះបន្ទាន់នៅពេលមានគ្រោះមហន្តរាយកើតឡើងនៅក្នុងសហគមន៍ | ៣.៨.៣ | ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់កុមាររងគ្រោះនិងងាយរងគ្រោះដោយគ្រោះមហន្តរាយដែលបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិនិងមនុស្សដូចជាទឹកជំនន់,រាំងស្ងួត, ខ្យល់ព្យុះ និងជម្ងឺឆ្លងរាតត្បាត។ល។ | ៥៦,០០០ | x | x | x | x | x | គ.គ.ម<br>ក.ក្រ.ក | រ.ថ.ជ |
| | (៤)គណៈកម្មាធិការថ្នាក់ខេត្ត ស្រុក និងឃុំនិងក្រុមគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ភូមិទទួលបានការពង្រឹងសមត្ថភាព | ៣.៨.៤ | ពង្រឹងសមត្ថភាព គណៈកម្មាធិការថ្នាក់ខេត្ត ស្រុក និងឃុំ និងក្រុមគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ភូមិ | ៦៥,០០០ | x | x | x | x | x | គ.គ.ម | រ.ថ.ជ |
| **សរុបចំណាយគោលដៅយុទ្ធសាស្ត្រទី២** | | | | ៨,០៤៦,៣០០ | | | | | | | |

[39] ច្បាប់យុត្តិធម៌អនីតិជន មាត្រា ១០.ការតែងតាំងនិងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច និងមាត្រា ១១.ភ្នាក់ងារសង្គមកិច្ច (ភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច)។

[40] ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (DRR)

[41] ការបន្សាំការប្រែប្រួលអាកាសធាតុ (CCA)

**គោលដៅយុទ្ធសាស្ត្រទី៣៖** លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង[42]

**គោលបំណង៖** ផ្សព្វផ្សាយពីការផ្លាស់ប្តូរឥរិយាបទសង្គមដោយធ្វើការដោះស្រាយឫសគល់នៃបញ្ហាកិច្ចការពារកុមារមិនគិតពីទំនៀមទម្លាប់ ប្រពៃណី ជំនឿ ពណ៌សម្បុរ ភេទ ភាសា នយោបាយឬទស្សនៈ ទ្រព្យសម្បត្តិ កំណើត ឋានៈនិងស្ថានភាពផ្សេងទៀតដល់ប្រជាជនទូទៅ ក្រុមគោលដៅផ្តល់សេវា និងអ្នកពាក់ព័ន្ធ ជាពិសេសយន្តការកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុក៖** ក្រុមគ្រួសារ សហគមន៍ អ្នកផ្តល់សេវា និងអ្នកពាក់ព័ន្ធមានការយល់ដឹងបញ្ហារបស់កុមារ និងផ្លាស់ប្តូរឥរិយាបទក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ

**ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| **យុទ្ធសាស្ត្រទី៣.១.ការលើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ[43]** | | | | | | | | | | | |
| (ក) **កម្រិតទី១៖**លើកកម្ពស់ការយល់ដឹងក្នុងណោមប្រជាជនទូទៅ | (១)ចំនួនឪកម្តាយឬអាណាព្យាបាល ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ អ្នកដឹកនាំសាសនា អ្នកស្ម័គ្រចិត្តតាមភូមិ អ្នកចិត្តខាង និងកុមារទទួលបានចំណេះដឹងអំពីការទប់ស្កាត់ភាពរងគ្រោះរបស់កុមារ | ៣.១.១ | អនុវត្តយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានសម្រាប់ឪពុកម្តាយឬអាណាព្យាបាល | ៥០,០០០ | x | x | x | x | x | ក.ក.ន | គ.ក.ន.ក |
| | | ៣.១.២ | ជំរុញនិងគាំទ្រសកម្មភាពផ្សព្វផ្សាយពីកិច្ចការពារកុមារដែលដឹកនាំដោយក្រុមកុមារនិងយុវជន | ៥៥,០០០ | x | x | x | x | x | ក.អ.យ.ក | គ.ក.ន.ក |
| | | ៣.១.៣ | រៀបចំនិងអនុវត្តផែនការសកម្មភាពស្តីពីកិច្ចការពារកុមារនៅក្នុងប្រព័ន្ធសាសនា | ៥២,០០០ | x | x | x | x | x | ក.ធ.ស. | រ.ថ.ជ |
| | | ៣.១.៤ | អនុវត្តផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់និងឆ្លើយតប (OCSE) | ៧៦,០០០ | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |
| | | ៣.១.៥ | ជំរុញការអនុវត្ត(Cambodia PROTECT) ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ | ៧៥,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |

[42] គោលដៅទី៣.២.៤៖លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែងនៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩

[43] យុទ្ធសាស្ត្រទី៤.៤.១.នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| (ខ) **កម្រិតទី២៖**លើកកម្ពស់ការយល់ដឹងក្នុងចំណោមក្រុមគោលដៅ និងតួអង្គពាក់ព័ន្ធ | (២)ចំនួនមន្ត្រីរាជការ នាយកឬម្ចាស់សហគ្រាស គ្រឹះស្ថាននិងសិប្បកម្ម អង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍ កុមារអនាថា កុមារបំរើតាមផ្ទះ និងកុមារធ្វើការនៅកន្លែងគ្រោះថ្នាក់ទទួលបាននូវចំណេះដឹងអំពីការទប់ស្កាត់ភាពងគ្រោះរបស់កុមារ | ៣.១.៦ | បញ្ចូលខ្លឹមសារកិច្ចការពារកុមារទៅក្នុងកម្មវិធីការអប់រំតាមបែបវិជ្ជមានដល់គ្រូបង្រៀននៅតាមសាលាគរុកុសល្យនិងវិក្រឹត្យការគ្រឹះស្ថានអប់រំសាធារណនិងសាលាឯកជន | ៧៥,000 | x | x | x | x | x | ក.អ.យ.ក | រ.ថ.ជ |
| | | ៣.១.៧ | លើកកម្ពស់ការយល់ដឹងនិងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈជាអ្នកសារព័ត៌មានក្នុងកិច្ចការពារកុមារតាមរយៈការអនុវត្តអ្នកសារព័ត៌មានបែបកុមារមេត្រី | ៦៦,000 | x | x | x | x | x | ក.ព.ម | រ.ថ.ជ |
| | | ៣.១.៨ | លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈក្នុងកិច្ចការពារកុមារ និងបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីវិជ្ជាជីវៈសុខាភិបាលទាំងមុនចេញបម្រើការងារនិងអ្នកកំពុងបម្រើការងារ | ៥៦,000 | x | x | x | x | x | ក.ស.ភ | រ.ថ.ជ |
| | | ៣.១.៩ | ពង្រឹងការអនុវត្តនីតិវិធីកុមារមេត្រី និងបញ្ចូលមេរៀនស្តីពីកិច្ចការពារកុមារ និងទៅក្នុងកម្មវិធីបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីអនុវត្តច្បាប់ | ៦៥,000 | x | x | x | x | x | ក.ម.ផ | រ.ថ.ជ |
| | | ៣.១.១០ | បណ្តុះបណ្តាលស្តីពីការអប់រំកុមារបែបវិជ្ជមានដល់អ្នកផ្តល់សេវាថែទាំកុមារនៅក្នុងមណ្ឌលរបស់រដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងនៅតាមសហគមន៍ | ៧៥,000 | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៣.១.១១ | ជំរុញការអនុវត្តកម្មវិធីអប់រំមាតាបិតាមា១៣ម៉ូឌុល ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា | ១០០,000 | x | x | x | x | x | ក.អ.យ.ក | រ.ថ.ជ |

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | | សកម្មភាពអនុវត្ត | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| | | ៣.១.១២ | ជំរុញនិងលើកទឹកចិត្តឱ្យនិស្សិត ក្រុមកុមារនិងយុវជនធ្វើការសិក្សាស្រាវជ្រាវអំពីកិច្ចការពារកុមារនិងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅតាមសហគមន៍ | ៥០,000 | x | x | x | x | x | ក.អ.យ.ក | រ.ថ.ជ |
| (គ) **កម្រិតទី៣៖**លើកកម្ពស់ការយល់ដឹងក្នុងចំណោមកុមាររងគ្រោះនិងគ្រួសារកុមាររងគ្រោះ | (៣)ចំនួនកុមាររងគ្រោះនិងក្រុមគ្រួសារទទួលបានចំណេះដឹងអំពីការទប់ស្កាត់ភាពរងគ្រោះរបស់កុមារសាជាថ្មី | ៣.១.១៣ | រៀបចំនិងអនុវត្តផែនការសកម្មភាពលុបបំបាត់ការរៀបការវ័យក្មេងនៅក្នុងសហគមន៍ជនជាតិដើមភាគតិច | ៥៥,000 | x | x | x | | x | ក.ក.ន | គ.ក.ន.ក |
| | | ៣.១.១៤ | ពង្រឹងសមត្ថភាពគ្រួសារ(តួនាទី ការសម្រេចចិត្ត និងជំនាញអប់រំកូនតាមបែបវិជ្ជមាន) | ៥៤,000 | x | x | x | x | x | ក.ក.ន | គ.ក.ន.ក |
| | | ៣.១.១៥ | លើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍ស្តីពីការទប់ស្កាត់គ្រោះថ្នាក់ការងារ និងការងារដោយបង្ខំ ឬការកេងប្រវ័ញ្ចមកលើកុមារដើម្បីផ្លាស់ប្តូរឥរិយាបទអ្នកពាក់ព័ន្ធចំពោះកុមារ | ៥៥,000 | x | x | x | x | x | ក.ក.ប.វ | គ.ក.ន.ក |
| | | ៣.១.១៦ | អប់រំឪពុកម្តាយ អ្នកថែទាំកុមារ លោកគ្រូឱ្យយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងវិធីទប់ស្កាត់ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ | ៦៥,000 | x | x | x | x | x | ក.ជ.ក<br>អ.ម.រ | រ.ថ.ជ |
| | | ៣.១.១៧ | លើកកម្ពស់ការយល់ដឹងពីការផ្តល់ព័ត៌មានអំពីការប្រព្រឹត្តបែបអវិជ្ជមានចំពោះកុមារ | ៧៥,000 | x | x | x | x | x | ក.ជ.ក<br>អ.ម.រ | រ.ថ.ជ |
| **យុទ្ធសាស្ត្រទី៣.២៖ការផ្លាស់ប្តូរឥរិយាបទសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ**[44] | | | | | | | | | | | |
| (ក) ការផ្លាស់ប្តូរឥរិយាបទសង្គមចំពោះករណីរំលោភបំពាន | (១)សហគមន៍មានការផ្លាស់ប្តូរឥរិយាបទបែបវិជ្ជមានចំពោះកុមាររងគ្រោះដោយសារករណីរំលោភបំពាន និង | ៣.២.១ | ផ្សព្វផ្សាយពីការផ្លាស់ប្តូរឥរិយាបទសង្គមដោយធ្វើការដោះស្រាយឫសគល់នៃបញ្ហាកិច្ចការពារកុមារមិនគិតពីទំនៀមទម្លាប់ ប្រពៃណី ជំនឿ | ៧០,000 | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |

[44] យុទ្ធសាស្ត្រទី៤.៤.២.នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| និងការកេងប្រវ័ញ្ចលើកុមារ | កេងប្រវ័ញ្ច | | ពណ៌សម្បុរ ភេទ ភាសា នយោបាយឬទស្សនៈ ទ្រព្យសម្បត្តិ កំណើត ឋានៈនិងស្ថានភាពផ្សេងទៀត | | | | | | | | |
| | | ៣.២.២ | តស៊ូមតិដើម្បីបង្កើតធនធានសម្រាប់ទប់ស្កាត់ និងដោះស្រាយករណីរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារ | ៥០,០០០ | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |
| | | ៣.២.៣ | លើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ផ្តល់ការគាំទ្រដល់កុមារនិងយុវជនចូលរួមក្នុងសកម្មភាពកិច្ចការពារកុមារនៅសហគមន៍ | ៥០,០០០ | x | x | x | x | x | ក.អ.យ.ក | គ.ក.ន.ក |
| (ខ) ពង្រឹងការអនុវត្តយុទ្ធសាស្ត្រនិងយន្តការដែលមានស្រាប់ដើម្បីកាត់បន្ថយហានិភ័យផ្សេងៗចំពោះកុមារនិងគ្រួសារ | (២)យន្តការកិច្ចការពារកុមារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិមានការផ្លាស់ប្តូរឥរិយាបទសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមាររងគ្រោះនិងងាយរងគ្រោះ | ៣.២.៤ | អនុវត្តផែនកាសកម្មភាពអនុវត្តដោយក្រសួងស្ថាប័នរដ្ឋក្នុងការលើកកម្ពស់ការយល់ដឹងស្របតាមយុទ្ធសាស្ត្រ Cambodia PROTECT, ការចិញ្ចឹមកូនតាមបែបវិជ្ជមាន និងការអប់រំតាមបែបវិជ្ជមាននៅតាមសាលារៀន | ៧៥,០០០ | x | x | x | x | x | ក.ជ.ក<br>ស.អ.យ | រ.ថ.ជ |
| | | ៣.២.៥ | ពង្រឹងយន្តការកិច្ចការពារកុមារដែលមានសម្រាប់ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅក្នុងវិស័យសាសនា ជនជាតិដើមភាគតិចសារព័ត៌មាន វិស័យសង្គមកិច្ច វិស័យការងារ វិស័យទេសចរណ៍ និងក្នុងប្រព័ន្ធអនឡាញ | ៧៥,០០០ | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |
| **សរុបការចំណាយគោលដៅយុទ្ធសាស្ត្រទី៣** | | | | **១,៤១៩,០០០** | | | | | | | |

**គោលដៅយុទ្ធសាស្ត្រទី៤៖ ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង**[45]

**គោលបំណង៖** ដើម្បីបង្ការទប់ស្កាត់ និងដោះស្រាយបញ្ហាប្រឈមរបស់កុមារដូចជា ការធ្វើពលកម្មធ្ងន់ធ្ងរ ចំណាកស្រុក ការញៀនគ្រឿងញៀន ភាពអនាថា ភាពពិការ ការរងអំពើហិង្សា ការជួញដូរ ការទំនាស់នឹងច្បាប់ ដោយជ្រើសរើសនិងកំណត់នូវអាទិភាពរបស់បញ្ហាប្រឈមទៅក្នុងប្រព័ន្ធកិច្ចការពារកុមារ។ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដែលតែងកើតមានហើយស្ត្រីជាម្តាយតែងតែរងគ្រោះដោយអំពើហិង្សារបស់ប្តី មានផលប៉ះពាល់ប្រាកដដល់កុមារដូចជា ការភ័យរន្ធត់ ការរំលោភបំពាន ការខកខានមិនបានទៅសាលារៀន។

**លទ្ធផលរំពឹងទុក៖** កុមារ និងគ្រួសាររងគ្រោះនិងងាយរងគ្រោះទទួលបាននូវការទប់ស្កាត់ អន្តរាគមន៍ និងផ្តល់សេវាគាំពារបញ្ចូលគ្នាដើម្បីកាត់បន្ថយបញ្ហាប្រឈមជាអាទិភាព។

**ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| **យុទ្ធសាស្ត្រទី៤.១៖កាត់បន្ថយបញ្ហាប្រឈមជាអាទិភាពរបស់កុមារ**[46] | | | | | | | | | | | |
| (ក) ឆ្លើយតបករណីរងគ្រោះរបស់កុមារី និងកុមារា | (១)អត្រាករណីរងគ្រោះនិងបញ្ហាប្រឈមរបស់កុមារនៅក្នុងសហគមន៍ត្រូវបានកាត់បន្ថយ | ៤.១.១ | លើកកម្ពស់ការអនុវត្តផ្លូវច្បាប់ពាក់ព័ន្ធនឹងការរំលោភបំពានលើកម្លាំងពលកម្មកុមារធ្ងន់ធ្ងរ | ៥០,០០០ | x | x | x | x | x | ក.អ.យ.ក | រ.ថ.ជ |
| | | ៤.១.២ | ផ្សព្វផ្សាយ និងអនុវត្តនីតិវិធីឆ្លើយតបកបដោយប្រសិទ្ធភាពដើម្បីបង្ការទប់ស្កាត់អំពើហិង្សាលើកុមារ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានតាមឪពុកម្តាយ | ៧៥,០០០ | x | x | x | x | x | ស.អ.យ | គ.ក.ន.ក |
| | | ៤.១.៣ | ពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពនិងលើកទឹកចិត្តឪពុកម្តាយ និងអាណាព្យាបាលចូលរួមដំណាក់កាលនៃការព្យាបាល និងស្តារនីតិសម្បទាកុមារញៀនគ្រឿងញៀននៅតាមសហគមន៍ | ១៥០,០០០ | x | x | x | x | x | ស.អ.យ | គ.ក.ន.ក |

[45] គោលដៅទី៣.២.៥៖ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែងនៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩

[46] យុទ្ធសាស្ត្រទី៤.៥.១.នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា (USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| | | ៤.១.៤ | ពង្រឹងគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថានិងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា រាជធានីខេត្ត | ៥០,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.១.៥ | ពង្រីករបបគោលនយោបាយឧបត្ថម្ភចំពោះជនពិការក្រីក្រនៅតាមសហគមន៍ និងផ្តល់ស្តារនីតិសម្បទាកុមារពិការភាព | ៧៦,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.១.៦ | បង្ការទប់ស្កាត់អំពើហិង្សាលើកុមារនៅក្នុងគ្រួសារនិងសហគមន៍ដោយជំរុញការអនុវត្តផែនការសកម្មភាពពាក់ព័ន្ធ | ៧៥,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.១.៧ | បង្ការទប់ស្កាត់ អន្តរាគមន៍ ផ្តល់កញ្ចប់សេវាឆ្លើយតបដល់កុមាររងគ្រោះនិងងាយរងគ្រោះ[47] | ៨០,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.១.៨ | អនុវត្តកម្មវិធីបង្វែរដើម្បីកាត់បន្ថយការអនុវត្តនីតិវិធីតុលាការនិងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសារជាថ្មីរបស់អនីតិជន | ៥០,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| (ខ) ឆ្លើយតបករណីរងគ្រោះរបស់ឪពុកម្តាយ ឬអាណាព្យាបាល | (២)អត្រាករណីអំពើហិង្សាក្នុងគ្រួសារនៅក្នុងសហគមន៍ត្រូវបានកាត់បន្ថយ | ៤.១.៩ | ពង្រឹង គ.ក.ន.ក ដើម្បីទប់ស្កាត់និងឆ្លើយតបករណីអំពើហិង្សាក្នុងគ្រួសារ | ១៦៤,៦០០ | x | x | x | x | x | ស.អ.យ | គ.ក.ន.ក |
| | | ៤.១.១០ | ផ្តល់កន្លែងសុវត្ថិភាពដល់អ្នករងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬរងគ្រោះដោយការរំលោភពីអ្នកដទៃ | ៥០,០០០ | x | x | x | x | x | ស.អ.យ | គ.ក.ន.ក |
| | | ៤.១.១១ | ផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬរងគ្រោះដោយការរំលោភពីអ្នកដទៃ | ៥០,០០០ | x | x | x | x | x | ស.អ.យ | គ.ក.ន.ក |

[47] ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ២០១៩-២០២៣ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | | សកម្មភាពអនុវត្ត | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| **យុទ្ធសាស្ត្រទី៤.២៖ការអនុវត្តកិច្ចការពារបញ្ចូលគ្នា**[48] | | | | | | | | | | | |
| (ក) ការផ្តល់សេវាទប់ស្កាត់ | (១)ចំនួនកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍ត្រូវបានគ្រប់គ្រងករណីនៅពេលជួបបញ្ហាប្រឈម | ៤.២.១ | ពិនិត្យនិងកែលម្អប្រព័ន្ធគ្រប់គ្រងករណីកុមារដែលស្របទៅនិងទៅជាឌីជីថល | ៧៥,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.២.២ | ជំរុញឱ្យមានយន្តការសហការរវាងប្រព័ន្ធរាយការណ៍បន្ទាន់របស់នគរបាល(Child Hotline) និងទូរសព្ទបន្ទាន់របស់អង្គការសង្គមស៊ីវិលដើម្បីឆ្លើយតបទាន់ពេលសម្រាប់កុមាររងគ្រោះនិងងាយរងគ្រោះ | ៥៥,០០០ | x | x | x | x | x | អ.ន.ប<br>អ.ម.រ | រ.ថ.ជ |
| | | ៤.២.៣ | សម្របសម្រួលនិងគាំទ្រការអនុវត្តប្រព័ន្ធទូរសព្ទជំនួយកុមារ(Child Helpline) | ៦០,០០០ | x | x | x | x | x | អ.ម.រ | រ.ថ.ជ |
| (ខ) ការផ្តល់សេវាអន្តរាគមន៍ | (២)ចំនួនកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍ទទួលបានកញ្ចប់សេវាអន្តរាគមន៍ | ៤.២.៤ | រៀបចំគោលនយោបាយស្តីពីកញ្ចប់សេវាមានលក្ខណៈប្រទាក់ក្រឡានិងរួមបញ្ចូលគ្នា(សេវាសុខុមាលភាពកុមារ សុខុមាលភាពគ្រួសារ សេវាសង្គ្រោះបឋម សេវាជំនួយផ្នែកច្បាប់ សេវាសង្គមកិច្ច សេវាស្តារនីតិសម្បទានិងសមាហរណកម្ម) | ៧៥,០០០ | | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.២.៥ | រៀបចំផែនទីសេវាទាំងសេវាសាធារណៈ និងសេវាអង្គការមិនមែនរដ្ឋាភិបាលនៅតាមឃុំ សង្កាត់ | ៥០,០០០ | x | x | x | x | x | | គ.ក.ន.ក |
| | | ៤.២.៦ | អនុវត្តសាកល្បងការផ្តល់កញ្ចប់សេវាចំពោះកុមាររងគ្រោះនិងងាយរងគ្រោះតាមរយៈប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ | ៧៥,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | | ៤.២.៧ | បង្កើនគោលការណ៍និងនីតិវិធីតាមដាននិងត្រួតពិនិត្យនូវគុណភាពការផ្តល់សេវាកិច្ចការពារកុមារ | ៧៥,០០០ | x | x | x | x | x | ក.ជ.ក | រ.ថ.ជ |

[48] យុទ្ធសាស្ត្រទី៤.៥.២.នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩

| ចង្កោមសកម្មភាព | សូចនាករលទ្ធផល | សកម្មភាពអនុវត្ត | | តម្រូវការថវិកា(USD) | ពេលវេលាអនុវត្ត ២០២១-២០២៥ | | | | | ស្ថាប័នអនុវត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | ថ្នាក់ជាតិ | ក្រោមជាតិ |
| (គ) ការឆ្លើយតប និងផ្តល់សេវា | (៣)ចំនួនកុមាររងគ្រោះ និងអនីតិជនដែលប្រព្រឹត្តបទល្មើស នឹងច្បាប់ទទួលបានសេវាផ្នែកច្បាប់ និងកម្មវិធីបង្វែរ | ៤.២.៨ | ផ្តល់សេវាគាំពារផ្នែកច្បាប់ដល់កុមាររងគ្រោះ និងអនីតិជនប្រព្រឹត្តបទល្មើសនៅក្នុងដំណើរការតុលាការ | ២៥,០០០ | x | x | x | x | x | ក.យ.ធ | រ.ថ.ជ |
| | | ៤.២.៩ | សេវាជាលក្ខណៈប្រមូលផ្តុំនៅមួយកន្លែងទោះក្នុងស្ថានភាពគ្រោះមហន្តរាយត្រូវបានកើនឡើង | ៧៥,០០០ | x | x | x | x | x | គ.គ.ម | គ.ក.ន.ក |
| | | ៤.២.១០ | ជំរុញការអនុវត្តផែនការបង្វែរអនីតិជនប្រព្រឹត្តបទល្មើស និងគ្រប់គ្រងការស្តារនីតិសម្បទានៅតាមសហគមន៍ | ៧៥,០០០ | x | x | x | x | x | ស.អ.យ | រ.ថ.ជ |
| | (៤)ចំនួនកុមារនៅក្នុងសហគមន៍ទទួលបានសេវាឆ្លើយតបនៅពេលមានគ្រោះមហន្តរាយកើតឡើង | ៤.២.១១ | រៀបចំបទដ្ឋានកិច្ចការពារកុមារនៅក្នុងស្ថានភាពហានិភ័យនិងគ្រោះមហន្តរាយស្របតាមបទដ្ឋានអប្បបរមាអន្តរជាតិស្តីពីកិច្ចការពារកុមារនៅក្នុងសកម្មភាពមនុស្សធម៌ | ៧៥,០០០ | x | x | x | x | x | គ.គ.ម | រ.ថ.ជ |
| | | ៤.២.១២ | បញ្ចូលបទដ្ឋានកិច្ចការពារកុមារនៅក្នុងក្របខណ្ឌគោលនយោបាយគ្រប់គ្រងគ្រោះមហន្តរាយ (ផែនការត្រៀម ឆ្លើយតបនិងអន្តរាគមន៍ និងសមាហរណកម្មបន្ទាប់ពីគ្រោះមហន្តរាយ) | ៦០,០០០ | x | x | x | x | x | គ.គ.ម | រ.ថ.ជ |
| | | ៤.២.១៣ | ពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធក្នុងសកម្មភាពឆ្លើយតបកិច្ចការពារកុមារនៅក្នុងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ៧២,០០០ | x | x | x | x | x | គ.គ.ម | រ.ថ.ជ |
| **សរុបការចំណាយគោលដៅយុទ្ធសាស្ត្រទី៤** | | | | **១,៧១៧,៦០០** | | | | | | | |

## ៤. ប្រភពហិរញ្ញប្បទាននិងចំណាយប៉ាន់ស្មាន

ដោយសារបញ្ហាកិច្ចការពារកុមារជាបញ្ហាអន្តរពហុវិស័យ ផែនការសកម្មភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារនេះ មិនកំណត់នូវថវិកា ប្រភពហិរញ្ញវត្ថុ និងចំណាយរួមមួយទេ។ ដោយឡែកប្រភពហិរញ្ញប្បទាននិងចំណាយប៉ាន់ស្មានសម្រាប់ការអនុវត្តសកម្មភាពត្រូវបានស្នើឡើងដោយក្រសួង-ស្ថាប័នអនុវត្តន៍ផ្ទាល់ដូចមានបង្ហាញនៅក្នុងតារាងម៉ាទ្រីសខាងលើ។ ជាសង្ខេប ថវិកា ប្រភពហិរញ្ញវត្ថុ និងចំណាយប៉ាន់ស្មាននេះត្រូវបានស្នើឡើងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធដូចមានសង្ខេបនៅក្នុងតារាងទី១ខាងក្រោម។

តារាងទី១៖តារាងតម្រូវការថវិកាសម្រាប់អនុវត្តគោលដៅយុទ្ធសាស្ត្រ

| ល.រ | គោលដៅយុទ្ធសាស្ត្រ | ប៉ាន់ប្រមាណតម្រូវការថវិកា(USD) | | |
|---|---|---|---|---|
| | | សរុបរួម | ថវិការដ្ឋ | ថវិកាដៃ |
| ១ | អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព | ១,៦៥៨,០០០ | ៦០% | ៤០% |
| ២ | រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ | ៨,០៤៦,៣០០ | ៧០% | ៣០% |
| ៣ | លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង | ១,៤១៩,០០០ | ៦០% | ៤០% |
| ៤ | ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង | ១,៧១៧,៦០០ | ៧០% | ៣០% |
| | **សរុបថវិកាចំណាយ** | **១២,៨៤០,៩០០** | **៦៥%** | **៣៥%** |

## ៥. សេចក្តីសន្និដ្ឋាន

ការសម្រេចបានដោយជោគជ័យនូវការអនុវត្ត**ផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥** ទាមទារនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នានិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងអ្នកមានចំណែក ពាក់ព័ន្ធទាំងអស់។ ទន្ទឹមនឹងនេះ ការវិភាជន៍ថវិកាសមស្របនឹងទាន់ពេលវេលាដល់កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពទាំងអស់ ដែលបានដាក់បញ្ចូលក្នុងតារាងម៉ាទ្រីស គឺជាលក្ខខណ្ឌដែលមិនអាចខ្វះបានចំពោះភាពជោគជ័យនៃការអនុវត្តផែនការសកម្មភាពនេះ។

ការសម្រេចបាននូវទិសដៅ**គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩** តាមរយៈការអនុវត្តផែនការសកម្មភាពតាមដំណាក់កាលទី១នឹងរួមចំណែកធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកិច្ចការពារកុមារ និងសុខុមាលភាពកុមារកម្ពុជា ជាពិសេសកុមាររងគ្រោះ និងងាយរងគ្រោះ ដែលអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករផលប៉ះពាល់ទាំងឡាយរបស់ផែនការសកម្មភាព៕

# ផ្នែកទី២៖ ផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថ្លៃចំណាយ

## ១. សេចក្តីផ្តើម

### ១.១. សាវតា និងបរិបទ

ការអភិវឌ្ឍធនធានមនុស្ស "កម្លាំងសេវាសង្គម"ត្រូវបានកំណត់ជាយុទ្ធសាស្ត្រមួយនៅក្នុងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩[49] ព្រោះថាធនធានមនុស្សដែលមានសមត្ថភាពនិងមានចំនួនគ្រប់គ្រាន់ទើបការអនុវត្តគោលនយោបាយជាតិនេះសម្រេចបានលទ្ធផលល្អ។ វិសាលភាពនៃកិច្ចការពារកុមារមានទំហំចាប់ពីកម្រិតទូទាំងប្រទេសរហូតដល់ថែកជាតំបន់ជនបទនិងទីប្រជុំជនដែលបន្តថែកចាយជាឃុំ សង្កាត់ ភូមិ និងចុងក្រោយបំផុតគឺខ្នងផ្ទះ ឬមណ្ឌលថែទាំកុមារ។ លក្ខណៈជាប្រព័ន្ធនៃធនធានមនុស្សត្រូវរួមបញ្ចូលមន្ត្រីរាជការទទួលបន្ទុកការងារកុមារក្នុងរចនាសម្ព័ន្ធ និងក្រសួងស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាជ្ញាធរមានសមត្ថកិច្ចតាមវិស័យពាក់ព័ន្ធត្រូវទទួលបានការអប់រំទូលាយ និងការបណ្តុះបណ្តាលអំពីបទដ្ឋានគតិយុត្តផ្នែកច្បាប់ នីតិវិធីអនុវត្តជាពហុវិស័យ ព្រមទាំងបទពិសោធន៍ជាក់ស្តែងតាមករណីដើម្បីឱ្យការអនុវត្តកិច្ចការពារប្រព្រឹត្តទៅដោយរលូននិងទទួលបានលទ្ធផលល្អទៅតាមប្រភេទកិច្ចការពារនីមួយៗ។

ចេញពីយុទ្ធសាស្ត្រនីមួយៗដែលបានដាក់ចេញនូវសកម្មភាពមួយចំនួន ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយជាតិនេះ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួង ស្ថាប័ន អាចប្រើប្រាស់ថវិការដ្ឋក្នុងក្របខ័ណ្ឌនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនព្រមទាំងកៀរគរមូលនិធិពីដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងពីប្រភពផ្សេងៗទៀតដើម្បីអនុវត្តសកម្មភាពនីមួយៗជាយុទ្ធសាស្ត្រគន្លឹះ។

### ១.២. គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩

គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ មានចក្ខុវិស័យធានាឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិស្មើៗគ្នា ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម មានសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិអភិវឌ្ឍន៍ និងសិទ្ធិចូលរួម។ ដើម្បីសម្រេចនូវចក្ខុវិស័យខាងលើក្នុងដំណាក់រយៈពេល១០ឆ្នាំខាងមុខ ចាំបាច់ត្រូវយកចិត្តទុកដាក់លើកកម្ពស់កិច្ចការពារកុមារបន្ថែមទៀត តាមរយៈការពង្រឹងការអនុវត្តប្រព័ន្ធកិច្ចការពារកុមារដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាពីគ្រប់ភាគីពាក់ព័ន្ធ សំដៅឆ្លើយតបទៅនឹងកិច្ចការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់ទម្រង់ដើម្បីឧត្តមប្រយោជន៍កុមារ។ គោលដៅសំខាន់ៗសម្រាប់ការអនុវត្តក្នុងរយៈពេល១០ឆ្នាំខាងមុខរួមមាន៖ ១.អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ឱ្យមានប្រសិទ្ធភាព ២.រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ ៣.អភិវឌ្ឍធនធានមនុស្ស ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ ៤.លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែងនិង៥.ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង។

គោលនយោបាយជាតិនេះ នឹងរួមចំណែកក្នុងការបន្តលើកកម្ពស់សុខុមាលភាព និងផលប៉ះពាល់ដល់ការអភិវឌ្ឍកុមារតាមរយៈការជំរុញឱ្យមានការបញ្ចូលបញ្ហាកិច្ចការពារកុមារទៅក្នុងផែនការអភិវឌ្ឍន៍គ្រប់វិស័យគ្រប់កម្រិតនិងនៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍជាតិ តំបន់និងសកល។ ដោយសារកិច្ចការពារកុមារមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងមានចរិតពហុវិស័យ ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារបាន

[49] គោលដៅទី៣.២.៣.អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ យុទ្ធសាស្ត្រ៤.៣.ក្នុងគោលដៅកសាងធនធានមនុស្សទាំងសមត្ថភាពការងារក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងទាំងចំនួនគ្រប់គ្រាន់នៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធសម្រាប់កិច្ចការពារកុមារ ជាពិសេសនៅតាមរដ្ឋបាលឃុំ សង្កាត់ និងភូមិ។

ចង្អុលបង្ហាញពីភាពចាំបាច់នៃការរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថវិកាលំអិតក្នុងការជួយដល់រាជរដ្ឋាភិបាលដើម្បីប្រែក្លាយគោលនយោបាយនេះទៅជាសកម្មភាពជាក់ស្តែងសំដៅសម្រេចបាននូវគោលបំណងនិងគោលដៅ។

## ២. ស្ថានភាព និងបញ្ហាប្រឈម

### ២.១. ស្ថានភាព

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្ត ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនដើម្បីពង្រឹងប្រព័ន្ធកិច្ចការពារកុមារទាំងការកសាងច្បាប់ លិខតបទដ្ឋានគតិយុត្ត និងយន្តការក្នុងការការពារ និងលើកកម្ពស់សិទ្ធិកុមារ។ ការលើកកម្ពស់សិទ្ធិជាមូលដ្ឋាន និងសេវាគាំទ្រកុមារនៅកម្ពុជា ត្រូវបានពង្រឹងកាន់តែប្រសើរតាមរយៈគម្រោងនិងកម្មវិធីកិច្ចសហប្រតិបត្តិការនានារបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស។ ក្នុងរយៈពេល២ទសវត្សកន្លងទៅនេះ ក្រោមការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ធ្វើឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលជាច្រើនដូចជាបានបង្កើតច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងបានបញ្ចូលបញ្ហារបស់កុមារទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព និងពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមនៅតាមក្រសួង ស្ថាប័ន និងយន្តការសម្របសម្រួលកិច្ចការពារកុមារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីផ្តល់សេវាដល់កុមាររងគ្រោះ និងងាយរងគ្រោះ។

សន្តិភាព ស្ថិរភាពនយោបាយនិងសន្តិសុខជាតិដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូរបស់ប្រជាជន។ ប្រជាជនកម្ពុជាបាន នឹងកំពុងទទួលផ្លែផ្កាពីសេចក្តីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងអត្រាមធ្យមប្រមាណ ៧,៧% នាអំឡុងពេលពីរទស្សវត្សរ៍កន្លងមកនេះ។ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយពី៥៣,២% នៅឆ្នាំ២០០៤ មកត្រឹម ១៣,៥% នៅឆ្នាំ២០១៤ និងបន្តធ្លាក់ចុះក្រោម១០% នៅឆ្នាំ២០១៨។ ចំណូលមនុស្សម្នាក់បានកើនពី៥៩០ USD ឆ្នាំ២០០៧ ដល់រង្វង់ ១.៥៦០ USD នៅឆ្នាំ២០១៨ និងកើនបន្តបន្ទាប់ទៀតបើមិនមានបញ្ហាប្រឈមដែលជាឧបសគ្គលើវិស័យសេដ្ឋកិច្ច។ ដោយមានកំណើនសេដ្ឋកិច្ចកើនឡើងរៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបានបង្កើន ថវិកាលើវិស័យសង្គមសង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀតក្នុងគោលដៅ ធ្វើឱ្យប្រសើរឡើងសុខុមាលភាពសង្គម និងកិច្ចការពារកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួង-ស្ថាប័នពាក់ព័ន្ធអាចប្រើប្រាស់ថវិការដ្ឋក្នុងក្របខ័ណ្ឌនៃថវិកាប្រចាំឆ្នាំរបស់ខ្លួនព្រមទាំងកៀរគរមូលនិធិពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ និងពីប្រភពផ្សេងៗទៀតដើម្បីធានាឱ្យបាននូវការអនុវត្តសកម្មភាពនីមួយៗដែលបានលើកឡើងនៅក្នុងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ។

### ២.២.បញ្ហាប្រឈម

រាជរដ្ឋាភិបាល បានវិនិយោគយ៉ាងច្រើន លើការកសាងសមត្ថភាពនិងការផ្តល់សេវាជួយដល់កុមារនិងគ្រួសាររងគ្រោះ និងងាយរងគ្រោះ ក្នុងនោះក៏មានការចូលរួមយ៉ាងសកម្មពីដៃគូពាក់ព័ន្ធ មានជាអាទិ៍ ដៃគូអភិវឌ្ឍ សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស វិស័យឯកជន និងសប្បុរសជនផងដែរ។ ប៉ុន្តែទោះជាមានការវិនិយោគនិងការជួយជ្រោមជ្រែងពីអ្នកពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏ធនធានមនុស្សនិងធនធានថវិកាទាំងនោះមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារនិងគ្រួសារនៅឡើយ។

កិច្ចការពារកុមារមានវិសាលភាពទូទាំងប្រទេសរហូតដល់ថែកជាតំបន់ជនបទ និងទីប្រជុំជនដែលបន្តថែកជាឃុំ សង្កាត់ ភូមិ និងចុងក្រោយបំផុតគឺខ្នងផ្ទះ ឬមណ្ឌលថែទាំកុមារ។ បើទោះបីជាយើងមានរចនាសម្ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងមានយន្តការ[50] ដែលចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តសព្វគ្រប់ហើយក្តី បើយើងគ្មានធនធានមនុស្ស"កម្លាំងសេវាសង្គម"ទាំងចំនួននិងសមត្ថភាពគ្រប់គ្រាន់ទេ មិនរំពឹងទុកថានឹងអាចសម្រេចបានល្អនូវគោលដៅដែលមានចែងនៅក្នុងគោលគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ។ បញ្ហាចោទនាពេលបច្ចុប្បន្នគឺកង្វះធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់[51] និងភូមិ។ ទន្ទឹមនឹងនេះសមត្ថភាពចំណេះដឹងនិងជំនាញកម្លាំងសេវាសង្គមដែលទទួលបន្ទុកកិច្ចការពារកុមារនៅមានកម្រិតនៅឡើយក្នុងការអនុវត្តបទដ្ឋានគតិយុត្ត និងនីតិវិធីផ្តល់សេវាជាប្រព័ន្ធពហុវិស័យ។ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សកិច្ចការពារកុមារឱ្យមានសមត្ថភាពសម្រាប់ដោះស្រាយបញ្ហាកិច្ចការពារកុមារ ដែលមានលក្ខណៈជាពហុវិស័យ គឺតម្រូវឱ្យមានផែនការអភិវឌ្ឍធនធានមនុស្សច្បាស់លាស់ដើម្បីសម្រេចបាននូវគោលដៅនៅក្នុងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ។

បញ្ហាប្រឈមចម្បងនៃធនធានមនុស្សទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិគឺដោយសារបញ្ហាកិច្ចការពារកុមារមានលក្ខណៈប្រព័ន្ធនិងប្រទាក់ក្រឡានិងការផ្តល់សេវាមានច្រើនប្រភេទ ព្រមទាំងអនុវត្តចាប់ពីថ្នាក់ជាតិដល់ថ្នាក់សហគមន៍ដែលធ្វើមានកង្វះខាតនូវចំនួនសមត្ថភាពនិងជំនាញមួយចំនួននៃធនធានមនុស្សនៅក្នុងស្ថាប័នសម្របសម្រួល និងអនុវត្ត គោលនយោបាយ។ កង្វះធនធានមនុស្សនៅថ្នាក់ឃុំ សង្កាត់ និងភូមិ ជាពិសេសអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ គាត់ធ្វើការមានអាណត្តិ៥ឆ្នាំម្តងតាមការបោះឆ្នោត ហើយគាត់គ្មានបុគ្គលិកជំនួយទេ ចំណែកភូមិក៏មានស្ថានភាពដូចគ្នាដែរ។ យុទ្ធសាស្ត្រនេះ ជាគន្លឹះនៅក្នុងគោលនយោបាយរបស់យើងដែលត្រូវតែទទួលបានការពិនិត្យរៀបចំឱ្យបានល្អ។ យើងអាចរកធនធានមនុស្សថ្មីជាបុគ្គលិកសង្គម ដែលមានជំនាញ ឬពាក់កណ្តាលជំនាញទាក់ទងនឹងកិច្ចការពារកុមារ តាមបែបបទក្នុងការរើសបុគ្គលិកជាប់កិច្ចសន្យា។

រាជរដ្ឋាភិបាលបានវិភាជថវិកាសម្រាប់អនុវត្តគោលនយោបាយមួយចំនួនដូចជាគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ និងគោលនយោបាយផ្សេងទៀតនៅមានកម្រិតនៅឡើយមិនអាចគ្រប់ដណ្តប់ដល់ជនរងគ្រោះនិងងាយរងគ្រោះនៅឡើយ។ ការវិភាជកញ្ចប់ថវិកាគាំទ្រប្រព័ន្ធកិច្ចការពារកុមារនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ[52] និងការគាំទ្រប្រព័ន្ធកិច្ចការពារកុមារភាគច្រើនពឹងផ្អែកលើការគាំទ្រធនធាន[53]ពីដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស តាមរយៈការអនុវត្តគម្រោង ឬកម្មវិធីដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ ផែនការសកម្មភាពជាតិនានានិងយុទ្ធសាស្ត្រដែលមានស្រាប់ពាក់ពន្ធ័នឹងកិច្ចការពារកុមារសុទ្ធតែមានបរិយាយអំពីធនធានហិរញ្ញវត្ថុរៀងៗខ្លួនប៉ុន្តែទំហំថវិកាវិភាជនៅមានកម្រិត[54] ដើម្បីអនុវត្តយុទ្ធសាស្ត្រក្នុងគោលនយោបាយជាតិនេះ។

---

[50] របាយការណ៍ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្ងៃទី១០ មករា ឆ្នាំ២០២០

[51] អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ធ្វើការមានអាណត្តិ៥ឆ្នាំម្តងតាមការបោះឆ្នោត ហើយគាត់គ្មានបុគ្គលិកជំនួយទេ។

[52] របាយការណ៍ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្ងៃទី១០ មករា ឆ្នាំ២០២០

[53] ធនធានរួមមាន៖ ថវិកា និងបច្ចេកទេស

[54] របាយការណ៍ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្ងៃទី១០ មករា ឆ្នាំ២០២០

## ៣. យុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្ស

ផ្អែកលើយុទ្ធសាស្ត្រទី១[55] និងទី២[56] នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមាររៀបចំឱ្យមានប្រព័ន្ធអ្នកទទួលខុសត្រូវនាំមុខ និងអ្នកទទួលខុសត្រូវពាក់ព័ន្ធដែលត្រូវដោះស្រាយទៅតាមប្រភេទនៃកិច្ចការពារដោយផ្អែកលើសសរស្តម្ភទាំងបី ការបង្ការទប់ស្កាត់ ការអន្តរាគម ការផ្តល់សេវាឆ្លើយតប ជាពហុវិស័យទាន់ពេលវេលាចំពោះកុមារគ្រប់រូប ដោយគ្មានការរើសអើង និងត្រូវឱ្យមានភាពប្រទាក់ក្រឡានិងស៊ីចង្វាក់គ្នា ចាប់ពីវិធានការបង្ការទប់ស្កាត់រហូតដល់ការឆ្លើយតបចំពោះកុមាររងគ្រោះ ឱ្យទទួលបានសុវត្ថិភាព ទាំងផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាព។ ក្នុងនោះកុមារគ្រប់រូបត្រូវទទួលបានការការពារដោយច្បាប់ កុមាររងគ្រោះនិងគ្រួសារត្រូវទទួលបានសេវាសមស្រប ត្រូវមានធនធានមនុស្សនិងថវិកាគ្រប់គ្រាន់សម្រាប់កិច្ចការពារកុមារ និងត្រូវផ្លាស់ប្តូរឥរិយាបថសង្គមចំពោះការប្រព្រឹត្តទៅលើកុមារ។

### ៣.១. គោលបំណង និងវិសាលភាព

ផែនការអភិវឌ្ឍន៍ធនធានមនុស្សមានគោលបំណងពង្រឹងសមត្ថភាព ជំនាញ និងវិជ្ជាជីវៈរបស់មន្ត្រីរាជការគ្រប់ប្រភេទដែលកំពុងបម្រើការងារនៅតាមក្រសួងស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបង្កើតចំនួនមន្ត្រីជំនាញតាមការចាំបាច់ក្នុងការបង្ការទប់ស្កាត់ អន្តរាគមន៍ និងការផ្តល់សេវាដើម្បីឆ្លើយតបចំពោះកុមារគ្រប់ៗរូបដែលរងគ្រោះពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាពឱ្យស្របតាមបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិក្នុងទិសដៅអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ផែនការនេះបានកំណត់គោលដៅដូចខាងក្រោម៖ (១)លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពនិងជំនាញនិងការត្រួតពិនិត្យតាមដានជាលក្ខណៈប្រមូលផ្តុំនិងសហប្រតិបត្តិការ(២)កំណត់នូវតួនាទីជំនាញជាក់លាក់ដែលត្រូវការបន្ថែមសម្រាប់អនុវត្តគោលដៅនីមួយៗ នៃគោលនយោបាយកាកិច្ចការពារកុមារនៅតាមស្ថាប័ននីមួយៗ (៣) កៀគរសមត្ថភាពនិងជំនាញដែលចាំបាច់ពីអង្គការដៃគូនិងស្ថាប័នជំនាញក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាពនិងប្រសិទ្ធភាព។

### ៣.២.យុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្ស

#### ៣.២.១.ការសិក្សាពីធនធានមនុស្សនៅក្នុងប្រព័ន្ធកិច្ចការពារកុមារ

ការសិក្សាជាមុននូវធនធានមនុស្សនេះអាចផ្តោតទៅលើប្រធានបទសំខាន់ៗទៅតាមសសរស្តម្ភទាំងបីនិងប្រព័ន្ធការពារកុមារដែលមានលក្ខណៈប្រទាក់ក្រឡានិងពហុវិស័យដែលមានចែងនៅក្នុងគោលនយោបាយជាតិមួយចំនួនក្នុងទិសដៅកំណត់បានច្បាស់លាស់និងជាក់លាក់នូវតម្រូវការនិងភាពខ្វះចន្លោះរបស់ធនធានមនុស្សមានដូចខាងក្រោម៖

**ក.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ**

ប្រព័ន្ធអប់រំ៖**ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធផ្សព្វផ្សាយ៖**ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសភាពាណិជ្ជកម្មកម្ពុជា**

វិស័យសាសនានិងទំនៀមទម្លាប់ជនជាតិដើមភាគតិច៖**ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងនឹងស្ត្រីនិងកុមារ៖**រដ្ឋបាលថ្នាក់ក្រោមជាតិ-អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ**

ប្រព័ន្ធសុខុមាលភាពគ្រួសារនិងការចិញ្ចឹមកូនតាមបែបវិជ្ជមាន៖**ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី**

---

[55] អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ឱ្យមានប្រសិទ្ធភាព

[56] រៀបចំនិងអនុវត្តប្រព័ន្ធកិច្ចការពារកុមារ ឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ

**ខ.ប្រព័ន្ធអន្តរាគមន៍**

យន្តការតុលាការ៖ **ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**

យន្តការនគរបាលយុត្តធម៌៖ **អគ្គស្នងការដ្ឋាននគរបាលជាតិ បណ្ឌិត្យសភានគរបាលកម្ពុជា កងរាជអាវុធហត្ថលើផ្ទៃប្រទេស**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងនឹងស្ត្រីនិងកុមារ៖ **រដ្ឋបាលថ្នាក់ក្រោមជាតិ-អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ**

**គ.ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា**

ប្រព័ន្ធសុខុមាលភាពកុមារនិងគ្រួសារ៖ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ប្រព័ន្ធអប់រំ៖ **ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធសុខាភិបាល៖ **ក្រសួងសុខាភិបាល**

ប្រព័ន្ធគាំពារសង្គម៖ **ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សភាពាណិជ្ជកម្មកម្ពុជា**

ប្រព័ន្ធរាយការណ៍៖ **អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ**

ប្រព័ន្ធទូរស័ព្ទជំនួយ៖ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

យន្តការភ្នាក់ងារផ្តល់សេវាសង្គមកិច្ច៖ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី**

យន្តការផ្តល់សេវាផ្នែកច្បាប់៖ **ក្រសួងយុត្តិធម៌និងគណៈមេធាវីកម្ពុជា**

យន្តការឆ្លើយតបគ្រោះមហន្តរាយ៖ **គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា**

**៣.២.២.ការរៀបចំនិងអនុវត្តការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព**

ការបណ្តុះបណ្តាលជំនាញឬចំណេះដឹងមានសារសំខាន់ក្នុងការអនុវត្តគោលនយោបាយជាតិសម្រាប់មន្ត្រីរាជការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ការបណ្តុះបណ្តាលមានប្រសិទ្ធភាពគឺផ្តោតទៅលើការបណ្តុះបណ្តាលជាកាតព្វកិច្ច ការប៉ាន់ប្រមាណតម្រូវការសមត្ថភាពក្រុមគោលដៅ ការអភិវឌ្ឍនូវសៀវភៅមេរៀន ការពង្រឹងសមត្ថភាពគ្រូបង្គោល និងការជំរុញនិងលើកទឹកចិត្តរៀនសូត្រដូចខាងក្រោម៖

- **ការបណ្តុះបណ្តាលជាកាតព្វកិច្ច៖** ជាការបណ្តុះបណ្តាលតាមមុខតំណែងនិងតួនាទីដោយមានការសម្រេចដោយប្រធានស្ថាប័នស្របតាមកម្មវិធីអភិវឌ្ឍន៍របស់ស្ថាប័ននីមួយៗ។ វិធីសាស្ត្រនេះមានគោលដៅលើកកម្ពស់ការបំពេញការងារប្រចាំថ្ងៃរបស់អង្គភាព បុគ្គល តាមរយៈការផ្តល់ចំណេះដឹង និងជំនាញដែលចាំបាច់ជាទៀងទាត់។
- **ការប៉ាន់ប្រមាណតម្រូវការសមត្ថភាពក្រុមគោលដៅ៖** គឺជាសកម្មភាពចាំចាច់សម្រាប់រៀបចំកម្មវិធីបណ្តុះបណ្តាល ដែលមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមគោលដៅទាំងលើការលើកកម្ពស់សមត្ថភាពនិងជំនាញ និងទាំងការបំពេញភាពខ្វះចន្លោះនៃសមត្ថភាពទៅតាមការវិភាគដែលស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយទៅលើការអនុវត្តតួនាទីនិងភារកិច្ច ឯកសារគតិយុត្តនិងលទ្ធផលនៃការសិក្សាជាមុនពីធនធានមនុស្សនៅក្នុងប្រព័ន្ធការពារកុមារខាងលើ។ ការប៉ាន់ប្រមាណនេះក៏ជួយឱ្យមន្ត្រីរាជការមានចំណេះដឹងជំនាញពាក់ព័ន្ធនឹងកិច្ចការពារកុមារស្របតាមការវិវត្តនៃសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យាទាំងក្នុងប្រទេស តំបន់ និងសកលលោក។
- **ការអភិវឌ្ឍសៀវភៅមេរៀន៖** ការអភិវឌ្ឍនូវសៀវភៅមេរៀនគឺមានឥទ្ធិពលទៅលើគុណភាពនៃការបណ្តុះបណ្តាល។ សៀវភៅមេរៀនត្រូវរៀបចំទុកជាមុននិងរួមមានប្លង់មេរៀន សៀវភៅមេរៀន សម្ភារធ្វើបទបង្ហាញ សម្ភារជំនួយ និងការវិភាគសមត្ថភាពមុននិងក្រោយការបណ្តុះបណ្តាល។ សៀវភៅមេរៀនត្រូវមានការ

ណែនាំអំពីការបង្រៀនសម្រាប់គ្រូបង្គោល មានលក្ខណៈជំរុញការចូលរួមពេញលេញពីក្រុមគោលដៅ និង ត្រួតពិនិត្យខ្លឹមសារឡើងវិញជាប្រចាំស្របតាមពេលវេលា និងការផ្លាស់ប្តូរបរិបទសង្គម មន្ត្រីរាជការ ឯកសារ គតិយុត្ត។ល។

- **ការពង្រឹងសមត្ថភាពគ្រូបង្គោលៈ** វិធីសាស្ត្រក្នុងការពង្រឹងសមត្ថភាពគ្រូបង្គោលត្រូវមានការពិចារណាឱ្យ បានហ្មត់ចត់ទៅតាមករណីនីមួយៗដូចជាគ្រូខ្វះពិសោធន៍ ទំហំការងារហួសកម្រិត ខ្វះការត្រៀមលក្ខណៈ ចំនួនសិក្ខាកាមច្រើនពេក។ល។ ដូចនេះវិធានការជាមូលដ្ឋានមួយចំនួនក្នុងការពង្រឹងសមត្ថភាពគ្រូបង្គោល មានដូចជាការផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោលឱ្យបានទៀងទាត់ គោរពគោលការណ៍ នៃការបណ្តុះ បណ្តាល និងការចាត់តាំងមន្ត្រីជាគ្រូបង្គោលឱ្យមានជំនាញជាក់លាក់ជាដើម។ ការជ្រើសរើសគ្រូបង្គោល ទាំងនៅក្នុងស្ថាប័នឬក្រៅស្ថាប័នត្រូវកំណត់ឱ្យបានច្បាស់លាស់ពីការរំពឹងទុក លក្ខណៈវិនិច្ឆ័យគ្រូបង្គោល និងពិនិត្យលំអិតពីប្លង់មេរៀនរបស់គ្រូបង្គោលដើម្បីជានាប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនីមួយៗ។
- **ការជំរុញនិងលើកទឹកចិត្តរៀនសូត្រៈ** នៅក្នុងស្ថាប័ននីមួយៗត្រូវបង្កបរិយាកាសជំរុញនិងលើកទឹកចិត្តមន្ត្រី ក្នុងការរៀនសូត្រតាមរយៈការតម្រង់ទិសនិងធ្វើបទបង្ហាញនៅមុនពេលបំពេញការងារពីវាគ្មិនដែលមាន ចំណេះដឹងនិងពិសោធន៍ច្រើននៅក្នុងស្ថាប័នរបស់ខ្លួនឬពីស្ថាប័នដទៃ ការរៀនសូត្របណ្តើរធ្វើការបណ្តើរ ដោយមានការណែនាំនិងបង្វឹកពីប្រធានផ្ទាល់ និងស្វ័យសិក្សា។ លើសពីនេះទៅទៀតដើម្បីឱ្យមន្ត្រីម្នាក់ៗ មានឆន្ទៈកាន់តែខ្លាំងក្នុងការរៀនសូត្រនិងអភិវឌ្ឍសមត្ថភាព ការភ្ជាប់ទំនាក់ទំនងរវាងការវាយតម្លៃគុណ ផលការងារនិងការអភិវឌ្ឍសមត្ថភាពគឺជាចំនុចសំខាន់ក្នុងការពិចារណាអនុវត្ត។ ប្រធានស្ថាប័ននីមួយៗ អាចរៀបចំការណែនាំនូវការផ្សារភ្ជាប់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការជាមួយប្រព័ន្ធគ្រប់គ្រងគុណ ផលមន្ត្រីរាជការ។ ក្នុងន័យនេះអង្គភាពគ្រប់គ្រងបុគ្គលិកទាំងនៅក្នុងស្ថាប័នថ្នាក់ជាតិនិងក្រោមជាតិអាច ដាក់បញ្ចូលការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការម្នាក់ៗទៅក្នុង លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃគុណ ផលការងាររបស់មន្ត្រីជាពិសេសក្នុងការតំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការតែងតាំងមុខតំណែងជាដើម។

### ៣.២.៣.ការបង្កើនចំនួនមន្ត្រីជំនាញសម្រាប់បង្ការទប់ស្កាត់ អន្តរាគមន៍ ឆ្លើយតបនិងផ្តល់សេវា

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារបានជោគជ័យ ចំនួនមន្ត្រីជំនាញនៅក្នុងស្ថាប័ន នីមួយៗគឺជាកត្តាសំខាន់ផងដែរក្នុងការអន្តរាគមន៍ ឆ្លើយតបនិងផ្តល់សេវាចំពោះកុមារជាពហុវិស័យនិងជាប្រព័ន្ធ។ ការបែងចែកតម្រូវការធនធានមនុស្សទៅតាមវិស័យសំខាន់ៗមួយចំនួនមានដូចក្នុងតារាងខាងក្រោមៈ

តារាងទី១ៈតម្រូវការតួនាទីឬមុខងារកិច្ចការពារកុមារ

| កិច្ចការពារកុមារ | ស្ថាប័នទទួលបន្ទុក | តម្រូវការតួនាទីឬមុខងារ |
|---|---|---|
| ការបង្ការទប់ស្កាត់ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | មន្ត្រីជំនាញកិច្ចការពារកុមារនៅក្នុងប្រព័ន្ធអនឡាន |
| | ក្រសួងព័ត៌មាន | មន្ត្រីដែលត្រូវពង្រឹងសមត្ថភាពនៃការផលិតនិងរៀបចំព័ត៌មាន ស្តីពីកុមារនិងកិច្ចការពារកុមារដើម្បីទទួលខុសត្រូវក្នុងការ ជួយពង្រឹងដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ឱ្យមាន ជំនាញនិងសមត្ថភាពត្រឹមត្រូវពីការផលិតព័ត៌មានស្តីពីកុមារ និងកិច្ចការពារកុមារដោយគោរពក្រមសីលធម៌វិជ្ជាជីវៈជា ពិសេសការមិនរំលោភលើឯកជនភាពកុមារ |
| បទអន្តរាគម | អគ្គស្នងការដ្ឋាន នគរបាលជាតិ | គួរមានមន្ត្រីនគរបាលជាស្ត្រីសម្រាប់ដោះស្រាយករណីកុមារ នៅគ្រប់ថ្នាក់ជាពិសេសនៅថ្នាក់មូលដ្ឋាន(នគរបាលស្ត្រីយ៉ាង |

៥៥/១

| កិច្ចការពារកុមារ | ស្ថាប័នទទួលបន្ទុក | តម្រូវការតួនាទីឬមុខងារ |
|---|---|---|
| | | តិចម្នាក់នៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ និងយ៉ាងតិច២នាក់នៅតាមអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ) |
| | កងរាជអាវុធហត្ថលើផ្ទៃប្រទេស | គួរមានមន្ត្រីកងរាជអាវុធហត្ថជាស្ត្រីឬមន្ត្រីទទួលបន្ទុកដោះស្រាយករណីកុមារនៅគ្រប់ថ្នាក់ជាពិសេសនៅថ្នាក់មូលដ្ឋាន |
| | ក្រសួងយុត្តិធម៌ | ព្រះរាជអាជ្ញា ចៅក្រម ក្រឡាបញ្ជី ដែលមានជំនាញនិងទទួលបន្ទុកលើករណីកុមារនៅគ្រប់តុលាការរាជធានី ខេត្ត និងតុលាការកំពូល |
| ការឆ្លើយតបនិងផ្តល់សេវា | ក្រសួង ស.អ.យ | - មន្ត្រីជាភ្នាក់ងារសង្គមកិច្ចអាជីពនៅកម្រិតមូលដ្ឋាន (អាចមាន៤នាក់ក្នុងមួយស្រុក ខណ្ឌ និងក្រុងនិងពេលអនាគតអាច១នាក់ក្នុង១ឃុំសង្កាត់)ទទួលខុសត្រូវលើករណីកុមាររួមទាំងការផ្តល់ប្រឹក្សាផ្នែកផ្លូវចិត្តដល់កុមារនិងគ្រួសាររបស់ពួកគេ<br>- មន្ត្រីធ្វើសមាហរណកម្មកុមារទៅសហគមន៍មានជំនាញច្បាស់លាស់(គួរមាន២នាក់ក្នុងមួយស្រុក ខណ្ឌ ក្រុង)<br>- មន្ត្រីទទួលបន្ទុកទូរសព្ទជំនួយកុមារដោយទំនាក់ទំនងជាមួយអង្គការទូរសព្ទជំនួយកុមារកម្ពុជាដើម្បីបង្កើនប្រសិទ្ធភាពនៃសេវា |
| | ក្រសួងសុខាភិបាល | វេជ្ជបណ្ឌិតនិងគិលានុបដ្ឋាកឯកទេសជំងឺកុមារនៅតាមបណ្ឌុលសុខភាពនិងមន្ទីរពេទ្យបង្អែក |
| | គណៈមេធាវីកម្ពុជា | មេធាវីផ្តល់សេវាឱ្យកុមាររងគ្រោះដោយមិនគិតថ្លៃ(មានយ៉ាងតិច២នាក់ក្នុង១ស្រុក ខណ្ឌ ក្រុង) |
| | អគ្គស្នងការដ្ឋាននគរបាលជាតិ | គួរមានមន្ត្រីនគរបាលប្រចាំការនៅក្នុងប្រព័ន្ធទូរសព្ទបន្ទាន់ការពារអនីតិជនដើម្បីជួយផ្តល់ប្រឹក្សាយោបល់ផ្នែកសង្គមកិច្ចវិទ្យានៅពេលកុមារឬគ្រួសាររាយការណ៍ |
| ការសម្របសម្រួលត្រួតពិនិត្យតាមដាន និងធ្វើរបាយការណ៍ | អគ្គលេខាធិការដ្ឋាន ក.ជ.ក<br><br>គណៈកម្មការជាតិពាក់ព័ន្ធទទួលបន្ទុក<br><br>ក្រសួង ស.អ.យ<br>ក្រសួងមហាផ្ទៃ<br>រដ្ឋបាលរាជធានីខេត្ត | **ក.ថ្នាក់ជាតិ**<br>- មន្ត្រីជំនាញផ្នែកប្រព័ន្ធការពារកុមារ មន្ត្រីជំនាញបង្ការទប់ស្កាត់ មន្ត្រីជំនាញផ្នែកច្បាប់កិច្ចការពារកុមារ មន្ត្រីជំនាញសង្គមកិច្ច មន្ត្រីត្រួតពិនិត្យតាមដាន វាយតម្លៃ និងរបាយការណ៍ នៅក្នុងផ្នែកការពារកុមារនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>- មន្ត្រីទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងគណកម្មាធិការជាតិដែលពាក់ព័ន្ធនឹងកុមារ រួមទាំងគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>**ខ.ថ្នាក់ក្រោមជាតិ** |

| កិច្ចការពារកុមារ | ស្ថាប័នទទួលបន្ទុក | តម្រូវការតួនាទីឬមុខងារ |
|---|---|---|
| | | - មន្ត្រីត្រួតពិនិត្យតាមដាន វាយតម្លៃនិងរបាយការណ៍នៅមន្ទីរសង្គមកិច្ចរាជធានី ខេត្ត<br>- អ្នកទទួលបន្ទុកកុមារ១បន្ថែមទៀតនៃគណកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ |

### ៣.២.៤.ការពង្រឹងនូវសកម្មភាពជួយផ្តល់ប្រឹក្សាឬហ្វឹកហ្វឺនដល់មន្ត្រីជំនាញ

ការអភិវឌ្ឍធនធានមនុស្សចាំបាច់សម្រាប់ផ្តល់ប្រឹក្សា ឬហ្វឹកហ្វឺនបន្ថែមដល់មន្ត្រីជំនាញនីមួយៗបន្ទាប់ពីការទទួលបានការអភិវឌ្ឍន៍សមត្ថភាពក្នុងការដោះស្រាយនូវបញ្ហាប្រឈមនៅពេលអនុវត្ត។ ពិភាក្សានូវគំនិតថ្មីៗសម្រាប់អនុវត្ត បង្កើននូវការយល់ដឹង និងជឿជាក់ទៅលើសមត្ថភាពរបស់ខ្លួន។ សកម្មភាពជួយផ្តល់ប្រឹក្សាឬហ្វឹកហ្វឺននេះត្រូវមាននៅក្នុងផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថវិកាសម្រាប់អនុវត្តនៅក្នុងស្ថាប័ននីមួយៗនិងអាចធ្វើឡើងក្នុងទម្រង់ជាកិច្ចប្រជុំដោយផ្ទាល់ឬតាមអនឡាញទៀងទាត់ និងសន្និបាតបូកសរុបការងារ និងលើកផែនការអនុវត្តបន្តជាប្រចាំឆ្នាំរបស់ស្ថាប័ននីមួយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៣.២.៥.ការរៀបចំកម្មវិធីស្តីពីកិច្ចការពារកុមារនៅក្នុងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសំខាន់ៗ

កិច្ចការពារកុមារ គឺជាបញ្ហាពហុវិស័យនិងផ្សារភ្ជាប់ទៅនឹងការអនុវត្តតួនាទីរបស់មន្ត្រីនៃវិស័យនីមួយៗ។ ការរៀបចំកម្មវិធីសិក្សាពាក់ព័ន្ធនឹងកិច្ចការពារកុមារនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ នៃវិស័យពាក់ព័ន្ធគឺចំបាច់បំផុតក្នុងការជំរុញការអនុវត្តផែនការអភិវឌ្ឍន៍ធនធានមនុស្សនៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារកាន់តែមានប្រសិទ្ធភាពនិងចីរភាព។ ការរៀបចំកម្មវិធីសិក្សាអំពីកិច្ចការពារកុមារអាចត្រូវបានពិចារណានិងយកទៅអនុវត្តដោយស្ថាប័នទទួលបន្ទុកនីមួយៗទៅតាមធនធាននិងស្ថានភាពជាក់ស្តែង។

តារាងទី២៖កម្មវិធីសិក្សាខាងក្រោមគឺជាចំនុចសម្រាប់ពិចារណាយកទៅអនុវត្ត

| គ្រឹះស្ថានអប់រំ និងវិទ្យាស្ថានជាតិ | កម្មវិធីសិក្សា |
|---|---|
| វិទ្យាស្ថានជាតិសង្គមកិច្ច | - ប្រព័ន្ធកិច្ចការពារកុមារ<br>- ជំនាញសង្គមកិច្ចផ្តោតលើករណីកុមារ និងគ្រប់គ្រងករណីកុមារ រួមទាំងយេនឌ័រ បរិយាបន្ន និងការចូលរួមរបស់កុមារ<br>- ជំនាញចិញ្ចឹមកូនតាមបែបវិជ្ជមាន |
| បណ្ឌិត្យសភានគរបាល | - ប្រព័ន្ធកិច្ចការពារកុមារ<br>- នីតិវិធីនគរបាលកុមារមេត្រី |
| រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ | - ប្រព័ន្ធកិច្ចការពារកុមារ<br>- នីតិវិធីតុលាការកុមារមេត្រី |
| វិទ្យាស្ថានជាតិអប់រំ និងមជ្ឈមណ្ឌលគរុកោសល្យនិងវិក្រិត្យការភូមិភាគ | - សាលារៀនសុវត្ថិភាពសម្រាប់កុមារពីការរំលោភបំពាននិងកេងប្រវ័ញ្ចគ្រប់រូបភាព<br>- ការអប់រំតាមបែបវិជ្ជមាន(ដោយមិនប្រើហិង្សា) រួមទាំងយេនឌ័របរិយាបន្ន និងការចូលរួមរបស់កុមារ |
| សកលវិទ្យាល័យភូមិន្ទភ្នំពេញ | មហាវិទ្យាល័យកិច្ចការសង្គម<br>- ប្រព័ន្ធកិច្ចការពារកុមារ |

| គ្រឹះស្ថានអប់រំ និងវិទ្យាស្ថានជាតិ | កម្មវិធីសិក្សា |
|---|---|
| | - ជំនាញសង្គមកិច្ចផ្តោតលើករណីកុមារ និងគ្រប់គ្រងករណីកុមារ រួមទាំងយេនឌ័របរិយាបន្ន និងការចូលរួមរបស់កុមារ មហាវិទ្យាល័យប្រព័ន្ធព័ត៌មាននិងទំនាក់ទំនង<br>- អ្នកសារព័ត៌មានបែបកុមារមេត្រី( សុវត្ថិភាពកុមារនៅក្នុងប្រព័ន្ធព័ត៌មាន ) |
| សាលាជាតិរដ្ឋបាលមូលដ្ឋាន | - រៀបចំនិងអនុវត្តផែនការឆ្លើយតបនឹងបញ្ហាកុមារនៃ គ.ក.ន.ក និងគ.ក.ស.កដែលមានប្រសិទ្ធភាព<br>- ការធ្វើផែនទីសេវាសង្គមនៅឃុំសង្កាត់<br>- យេនឌ័រ បរិយាបន្ន និងការចូលរួមរបស់កុមារនៅក្នុងកិច្ចការពារកុមារ<br>- ការគ្រប់គ្រងនិងត្រួតពិនិត្យការថែទាំកុមារនៅក្នុងមណ្ឌល<br>- សម្របសម្រួលសេវាដល់កុមាររងគ្រោះរួមទាំងការធ្វើសមាហរណកម្មកុមារទៅក្នុងសហគមន៍ |

កម្មវិធីសិក្សាផ្សេងទៀត នឹងមាននៅក្នុងរបាយការណ៍សិក្សាជាមុនស្តីពីធនធានមនុស្សនៅក្នុងប្រព័ន្ធកិច្ចការពារកុមារដែលតម្រូវឱ្យស្ថាប័ននីមួយៗពិចារណានៅក្នុងគ្រឹះស្ថានឬវិទ្យាស្ថានជាតិដែលពាក់ព័ន្ធក្នុងការឆ្លើយតបបញ្ហាកិច្ចការពារកុមារ។ កម្មវិធីសិក្សានីមួយៗគួរមានការវាយតម្លៃនិងធ្វើបច្ចុប្បន្នភាពជាប្រចាំទៅតាមការប្រែប្រួលគោលនយោបាយ សង្គម និងសេដ្ឋកិច្ចទាំងនៅក្នុងប្រទេស តំបន់ និងអន្តរជាតិ។

### ៣.២.៦.ការបង្កើនកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សអំពីប្រព័ន្ធការពារកុមារត្រូវការចាំបាច់នូវកិច្ចសហការ និងសម្របសម្រួលល្អពីគ្រប់ភាគីពាក់ព័ន្ធទាំងក្នុងនិងក្រៅស្ថាប័ន។ កិច្ចសហប្រតិបត្តិការអាចអនុវត្តជាមួយអង្គភាពនានាចំណុះស្ថាប័ន វិទ្យាស្ថានជាតិ គ្រឹះស្ថានបណ្តុះបណ្តាល ដៃគូអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិលដើម្បីជំរុញកិច្ចសហការបច្ចេកទេស និងថវិកាក្នុងទិសដៅសម្រេចឱ្យបាននូវផែនការអភិវឌ្ឍធនធានមនុស្សដូចខាងក្រោម៖

- **ការកសាងបណ្តាញអ្នកជំនាញ៖** ការកសាងបណ្តាញនៅគ្រប់ភាគីពាក់ព័ន្ធនៃរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាទាំងក្នុងប្រទេស តំបន់ និងអន្តរជាតិទៅតាមវិស័យនៃការអភិវឌ្ឍធនធានមនុស្សសំដៅចែករំលែកធនធានមនុស្សទៅវិញទៅមក ចំណេះដឹងនិងជំនាញផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ និងការសម្របសម្រួលការអភិវឌ្ឍសមត្ថភាពរួមគ្នាឬជាលក្ខណៈប្រមូលផ្តុំ។
- **កិច្ចសហប្រតិបត្តការផ្នែកបច្ចេកទេស៖** កិច្ចសហប្រតិបត្តិការបច្ចេកទេសសំដៅកិច្ចសហការក្នុងការគាំទ្រនិងចែករំលែកធនធានមនុស្សដែលមានចំណេះដឹង ជំនាញ និងពិសោធន៍ស្តីពីប្រធានបទជាក់លាក់ណាមួយនៅក្នុងប្រព័ន្ធការពារកុមារ។ កិច្ចសហការនេះអាចធ្វើបានជាមួយស្ថាប័ន គ្រឹះស្ថានសាធារណៈ ឬឯកជន ដៃគូអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិទៅតាមតម្រូវការបច្ចេកទេសជាក់ស្តែង។
- **កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍសមត្ថភាពថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ៖** ការអភិវឌ្ឍសមត្ថភាពត្រូវតែផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួតរវាងថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិក្នុងទិសដៅចែករំលែកចំណេះដឹង ពិសោធន៍ និងជំនាញទៅវិញទៅមកពីថ្នាក់ជាតិទៅដល់ថ្នាក់សហគមន៍។ ក្រសួង ស្ថាប័នត្រូវពង្រឹងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្ទេរមុខងារប្រកបដោយប្រសិទ្ធភាព និងពង្រឹង

បង្កើនសមត្ថភាពពីសំណាក់ស្ថាប័នថ្នាក់ជាតិទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគោលនយោបាយ។

- **កិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរការសិក្សា៖** កិច្ចសហការនេះអាចធ្វើឡើងតាមរយៈកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីមួយៗជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ស្ថាប័ននៅតំបន់និងអន្តរជាតិដើម្បីចែករំលែកនូវចំណេះដឹង ពិសោធន៍ និងពង្រឹងសមត្ថភាពគ្នាទៅវិញទៅមកទាំងរយៈពេលវែងខ្លី និងរយៈពេលវែង ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។ កិច្ចសហការក្នុងការផ្លាស់ប្តូរការសិក្សាអាចមានរូបភាពជាការចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា កម្មសិក្សា កម្មវិធីផ្លាស់ប្តូរពិសោធន៍ ។ល។
- **កិច្ចសហប្រតិបត្តិការផ្នែកធនធានហិរញ្ញវត្ថុ៖** កិច្ចសហប្រតិបត្តិការផ្នែកធនធានហិរញ្ញវត្ថុសំដៅលើការគាំទ្រផ្នែកថវិកា សម្ភារ និងឧបករណ៍បរិក្ខារពីក្រសួងស្ថាប័នសាមី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ កិច្ចសហការអាចធ្វើឡើងដោយស្ថាប័ននីមួយៗជាប្រចាំឆ្នាំ ឬតាមតម្រូវការជាក់ស្តែងតាមរយៈការលើកជាសំណើគម្រោង ឬការរៀបចំផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ធនធានមនុស្ស ឬតាមកិច្ចប្រជុំទៀងទាត់ជាមួយក្រសួងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ។

សកម្មភាពយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សខាងលើនេះដាក់បញ្ចូល ក្នុងតារាងម៉ាទ្រីសខាងដែលជាផ្នែកមួយដ៏សំខាន់សម្រាប់ចង្អុលបង្ហាញពីតម្រូវការថវិកាពីប្រភពរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ដើម្បីអភិវឌ្ឍធនធានមនុស្សសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩។ តារាងម៉ាទ្រីសនេះ គឺជាឧបករណ៍ស្នូលសម្រាប់វាស់វែងអំពីថវិកាដែលកៀរគរបាន ថវិកាដែលត្រូវការបន្ថែម និងការចូលរួមពីស្ថាប័នទទួលខុសត្រូវនិងស្ថាប័នជួយគាំទ្រ។

## តារាងម៉ាទ្រីសនៃផែនការអភិវឌ្ឍន៍ធនធានមនុស្សស្របទៅតាមគោលដៅនៃគោលនយោបាយ

| គោលដៅ គោលនយោបាយ | សូចនាករ | សកម្មភាពអនុវត្ត | តម្រូវការថវិកា (US$) | ឆ្នាំអនុវត្ត | ស្ថាប័នអនុវត្ត និងគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ស្ថាប័នអនុវត្ត | ស្ថាប័នគាំទ្រ |
| **គោលដៅទី៣.២.១៖ អភិវឌ្ឍ និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព** | (១)អ្នកអនុវត្តច្បាប់មានជំនាញនីតិវិធីនគរបាលកុមារមេត្រី | ១.១ ពិនិត្យឡើងវិញនូវមេរៀនដែលមានស្រាប់និងអនុវត្តនៅក្នុងកម្មវិធីសិក្សានៅបណ្ឌិត្យសភានគរបាលកម្ពុជា | ៥០,000 | ឆ្នាំ២០២២<br>ឆ្នាំ២០២៥ | បណ្ឌិត្យសភានគរបាលកម្ពុជា | ក្រសួងមហាផ្ទៃនិង អគ្គស្នងការនគរបាលជាតិ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ១.២ ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលពីនីតិវិធីនគរបាលកុមារមេត្រីដល់មន្ត្រីនគរបាលជាតិនិងនៅតាមមូលដ្ឋាន និងមេធាវី | ៨០,000 | ឆ្នាំ២០២២<br>ឆ្នាំ២០២៣<br>ឆ្នាំ២០២៦<br>ឆ្នាំ២០២៧ | សាលានគរបាលភូមិភាគ | អគ្គស្នងការនគរបាលជាតិ និងរដ្ឋបាលរាជធានីខេត្ត ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ១.៣ ពិនិត្យឡើងវិញនូវមេរៀនដែលមានស្រាប់និងអនុវត្តនៅក្នុងកម្មវិធីសិក្សានៅរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ | ៥០,000 | ឆ្នាំ២០២២<br>ឆ្នាំ២០២៥ | រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ | ក្រសួងយុត្តិធម៌ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ១.៤ ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលពីនីតិវិធីតុលាការកុមារមេត្រីដល់មន្ត្រីតុលាការដូចជាតុលាការរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវី | ៨០,000 | ឆ្នាំ២០២២<br>ឆ្នាំ២០២៣<br>ឆ្នាំ២០២៦<br>ឆ្នាំ២០២៧ | រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ មន្ទីរយុត្តិធម៌ រាជធានីខេត្ត | ក្រសួងយុត្តិធម៌ គណមេធាវីកម្ពុជា រដ្ឋបាលរាជធានីខេត្ត ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| **គោលដៅទី៣.២.២៖ រៀបចំ និងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ** | (២)អ្នកអនុវត្តប្រព័ន្ធកិច្ចការពារកុមារមានជំនាញគ្រប់គ្រងទិន្នន័យកុមារនិងកិច្ចការពារការនិងធ្វើរបាយការណ៍ពីស្ថានភាព | ២.១ ជ្រើសរើសមន្ត្រីគ្រប់គ្រងទិន្នន័យកិច្ចការពារកុមារនៅអគ្គលេខាធិកាដ្ឋាន ក.ជ.ក និងលេខាធិការដ្ឋាន ក.ជ.ក រាជធានីខេត្ត | ៤៥,000 | ឆ្នាំ២០២២ | អគ្គលេខាធិការដ្ឋាន ក.ជ.ក រដ្ឋបាលរាជធានីខេត្ត | វិទ្យាស្ថានជាតិស្ថិតិ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ២.២ បណ្ដុះបណ្ដាលជំនាញគ្រប់គ្រងទិន្នន័យកុមារនិងការធ្វើរបាយការណ៍ពីស្ថានភាពកុមារដល់មន្ត្រីនៅលេខាធិកាដ្ឋាននៃក.ជ.ក រាជធានីខេត្ត | ៦០,000 | ឆ្នាំ២០២២<br>ឆ្នាំ២០២៤<br>ឆ្នាំ២០២៧ | អគ្គលេខាធិការដ្ឋាន ក.ជ.ក រដ្ឋបាលរាជធានីខេត្ត | វិទ្យាស្ថានជាតិស្ថិតិ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |

| គោលដៅគោលនយោបាយ | សូចនាករ | | សកម្មភាពអនុវត្ត | តម្រូវការថវិកា (US$) | ឆ្នាំអនុវត្ត | ស្ថាប័នអនុវត្ត និងគាំទ្រ | |
|---|---|---|---|---|---|---|---|
| | | | | | | ស្ថាប័នអនុវត្ត | ស្ថាប័នគាំទ្រ |
| | | | និងមន្ត្រីទទួលបន្ទុកគ្រប់គ្រងទិន្នន័យនៃស្ថាប័នជាសមាជិក ក.ជ.ក នៅថ្នាក់ជាតិ | | | | |
| | (៣)អ្នកអនុវត្តប្រព័ន្ធកិច្ចការពារកុមារមានសមត្ថភាពសម្របសម្រួលនិងឆ្លើយតបកិច្ចការពារកុមារនៅតាមវិស័យ | ២.៣ | ជ្រើសរើសជនបង្គោលទទួលបន្ទុកកុមារម្នាក់បន្ថែមនៅតាមឃុំ សង្កាត់ និងកែសម្រួលតួនាទីរបស់ គ.ក.ន.ក | ១២០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៣ | ក្រុមប្រឹក្សាឃុំសង្កាត់ | ក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានីខេត្ត |
| | | ២.៤ | កំណត់និងកែសម្រួលតួនាទីមន្ត្រីទទួលបន្ទុកកុមារនៅក្នុងស្ថាប័នគាំពារសង្គម ប្រឆាំងការជួញដូរ ប្រឆាំងគ្រឿងញៀន លើកកម្ពស់ពិការភាព និងសិទ្ធិមនុស្ស | ៥០,០០០ | ឆ្នាំ២០២២ | គណកម្មាធិការជាតិទទួលបន្ទុក | អគ្គលេខាធិការដ្ឋាន ក.ជ.ក |
| | | ២.៥ | បង្កើនការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុក ជំរុញការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ បង្កើនការអប់រំ ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ព្រមទាំងលើកកំពស់ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធជាតិ-អន្តរជាតិនៅក្នុងប្រទេសគោលដៅក្នុងកិច្ចការពារ និងសង្គ្រោះកុមារ | ៨០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៤ ឆ្នាំ២០២៧ | អគ្គរាជទូត | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ |
| **គោលដៅទី៣.២.៣៖ អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ** | (៤)អ្នកអនុវត្តច្បាប់មានសមត្ថភាពសម្របសម្រួលក្នុងការអនុវត្តកិច្ចការពារកុមារ | ៣.១ | ជ្រើសរើសមន្ត្រីជំនាញផ្នែកច្បាប់ ផ្នែកប្រព័ន្ធការពារកុមារ ផ្នែកសង្គមកិច្ច ផ្នែកបង្ការទប់ស្កាត់ ផ្នែកការចូលរួមរបស់កុមារនិងបរិយាប័នមកបំពេញការងារនៅក្នុងផ្នែកកិច្ចការពារកុមារនៃអគ្គលេខាធិការ ក.ជ.ក | ១២០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៣ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ក្រសួងមុខងារសាធារណៈ |
| | (៥)មន្ត្រីមានសមត្ថភាពដោះស្រាយករណីកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ និងការផ្តល់សេវា | ៣.២ | រៀបចំសមាភាពមន្ត្រីនគរបាលជានារីឱ្យបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់និងជាទិសដៅនគរបាលជានារីយ៉ាងតិច២នាក់ | ២៥០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៦ | អគ្គស្នងការដ្ឋាននគរបាលជាតិ ស្នងការនគបាលរាជធានីខេត្ត | ក្រសួងមុខងារសាធារណៈ រដ្ឋបាលរាជធានី ខេត្ត |

| គោលដៅ គោលនយោបាយ | សូចនាករ | សកម្មភាពអនុវត្ត | តម្រូវការថវិកា (US$) | ឆ្នាំអនុវត្ត | ស្ថាប័នអនុវត្ត និងគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ស្ថាប័នអនុវត្ត | ស្ថាប័នគាំទ្រ |
| | | ៣.៣ កែសម្រួលមុខងារនៅតាមតុលាការគ្រប់កម្រិត ដោយកំណត់ឱ្យបានជាក់លាក់នូវអ្នកទទួលបន្ទុកដោះស្រាយករណីកុមារ(ចៅក្រម រាជអជ្ញា ក្រឡាបញ្ជី។ល។) | ៨០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៧ | តុលាការ រាជធានីខេត្ត | ក្រសួងយុត្តិធម៌ និង រដ្ឋបាលរាជធានី ខេត្ត |
| | | ៣.៤ កំណត់តួនាទីនិងការទទួលខុសត្រូវព្រមទាំងមេធាវីដែលទទួលបន្ទុកករណីកុមារនៅគ្រប់រាជធានីខេត្តក្នុងការផ្តល់សេវាដោយឥតគិតថ្លៃដល់កុមារនិងគ្រួសារ | ៦០,០០០ | ឆ្នាំ២០២២ | គណៈមេធាវី កម្ពុជា | គណៈរដ្ឋមន្ត្រី |
| | | ៣.៥ បង្កើតកម្មវិធីសិក្សាច្បាស់លាស់ពីភ្នាក់ងារសង្គមកិច្ចអាជីពនិងបញ្ចូលនៅក្នុងកម្មវិធីរបស់គ្រឹះស្ថានរបស់រដ្ឋជាពិសេសភ្នាក់ងារសង្គមកិច្ចលើករណីកុមាររួមទាំងយេនឌ័របរិយាបន្ន និងការចូលរួមរបស់កុមារ | ៨០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៣ | វិទ្យាស្ថានជាតិ សង្គមកិច្ច និង សកលវិទ្យាល័យ ភូមិន្ទភ្នំពេញ | ក្រសួង ស.អ.យ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ៣.៦ កំណត់នូវគុណវុឌ្ឍិ និងឯកទេសនៃកម្លាំងសេវាសង្គមនិងរៀបចំនីតិវិធីក្នុងការផ្តល់អជ្ញាបណ្ណ | ៧០,០០០ | ឆ្នាំ២០២២ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិង យុវនីតិសម្បទា | ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ៣.៧ ជ្រើសរើសអ្នកសង្គមកិច្ចអាជីព និងអ្នកសង្គមកិច្ចអាជីពរង និងអ្នកសង្គមកិច្ចមិនអាជីពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសមន្ត្រីនៅក្រុងស្រុកខណ្ឌដែលទទួលបន្ទុកគ្រប់គ្រងករណីកុមារ | ១២០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៤ | រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរ ស.អ.យ | ក្រសួង ស.អ.យ ក្រសួងមហាផ្ទៃ និង ដៃគូអភិវឌ្ឍន៍ |
| | | ៣.៨ ជ្រើសរើសនិងបែងចែកមុខងាររដ្ឋបណ្ឌិតនិងគិលានុបដ្ឋាកឯកទេសជំងឺកុមារបន្ថែមទៅតាមមន្ទីរបង្អែកនិងមណ្ឌលសុខភាព | ៦០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៤ | មន្ទីរសុខាភិបាល រាជធានី ខេត្ត | ក្រសួងសុខាភិបាល រដ្ឋបាលរាជធានីខេត្ត |

| គោលដៅ គោលនយោបាយ | សូចនាករ | សកម្មភាពអនុវត្ត | តម្រូវការថវិកា (US$) | ឆ្នាំអនុវត្ត | ស្ថាប័នអនុវត្ត និងគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ស្ថាប័នអនុវត្ត | ស្ថាប័នគាំទ្រ |
| | | ៣.៩ បង្កើតការិយាល័យទទួលបន្ទុកកិច្ចការពារកុមារនៅក្នុងប្រព័ន្ធអនឡាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ៥០,០០០ | ឆ្នាំ២០២២ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អគ្គលេខាធិការ ក.ជ.ក ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ៣.១០ បណ្តុះបណ្តាលសាលារៀនសុវត្ថិភាពដើម្បីកុមារពីការរំលោភបំពាននិងកេងប្រវ័ញ្ចគ្រប់ទម្រង់នៅក្នុងកម្មវិធីសិក្សានៃការបណ្តុះបណ្តាលគ្រូ | ១០០,០០០ | ឆ្នាំ២០២២ និងជាប្រចាំ | វិទ្យាស្ថានជាតិអប់រំ មជ្ឈមណ្ឌលគរុកោសល្យនិង វិក្រិត្យកាលភូមិភាគ | ក្រសួងអប់រំ យុវជន និង កីឡា ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ៣.១១ បណ្តុះបណ្តាល គ.ក.ន.ក និង គ.ក.ស.ក អំពីការធ្វើផែនទីសេវាសង្គម ការសម្របសម្រួលធ្វើសមាហរណកម្មកុមារ | ១៦០,០០០ | ឆ្នាំ២០២២ និងជាប្រចាំ | | ក្រសួងមហាផ្ទៃ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ៣.១២ រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការពារកុមារនៅតាមកម្មវិធីសិក្សាបរិញ្ញាប័ត្រសង្គមកិច្ច | ៨០,០០០ | ឆ្នាំ២០២១ និងជាប្រចាំ | វិទ្យាស្ថានជាតិ សង្គមកិច្ច សកលវិទ្យាល័យ ភូមិន្ទភ្នំពេញ វិទ្យាស្ថានសន្តប៉ូល | ក្រសួង ស.អ.យ និង ក្រសួងអប់រំ យុវជន និង កីឡា ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | | ៣.១៣ បញ្ចូលកម្មវិធីកិច្ចការពារកុមារនៅក្នុងប្រព័ន្ធព័ត៌មាននៅក្នុងបរិញ្ញាប័ត្រគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងទំនាក់ទំនង | ៦៥,០០០ | ឆ្នាំ២០២២ និងជាប្រចាំ | សកលវិទ្យាល័យ ភូមិន្ទភ្នំពេញ | ក្រសួងអប់រំ យុវជន និង កីឡា ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| **គោលដៅទី៣.២.៤៖ លើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារ នៅគ្រប់ទីកន្លែង** | (៦)មន្ត្រីមានជំនាញការចិញ្ចឹមកូននិងការអប់រំតាមបែបវិជ្ជមាន និងការចូលរួមរបស់កុមារ | ៤.១ បណ្តុះបណ្តាលសមាជិក គ.ក.ន.ក, គ.ក.ស.ក អំពីការចិញ្ចឹមកូនតាមបែបវិជ្ជមាន យេនឌ័រនិងបរិយាបន្ននិងការគាំទ្រសកម្មភាពដឹកនាំដោយក្រុមកុមារនិងយុវជននៅក្នុងកិច្ចការពារកុមារ | ១២០,០០០ | ឆ្នាំ២០២៣ ឆ្នាំ២០២៧ | | |
| | | ៤.២ បណ្តុះបណ្តាលគ្រូបង្រៀននៅតាមគ្រឹះស្ថានអប់រំសាធារណៈនិងឯកជនអំពីការអប់រំតាមបែប | ១៤០,០០០ | ឆ្នាំ២០២២ ឆ្នាំ២០២៥ ឆ្នាំ២០២៧ | ក្រសួងអប់រំ មន្ទីរអប់រំរាជធានី ខេត្ត | រដ្ឋបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |

| គោលដៅគោលនយោបាយ | សូចនាករ | សកម្មភាពអនុវត្ត | តម្រូវការថវិកា (US$) | ឆ្នាំអនុវត្ត | ស្ថាប័នអនុវត្ត និងគាំទ្រ | |
|---|---|---|---|---|---|---|
| | | | | | ស្ថាប័នអនុវត្ត | ស្ថាប័នគាំទ្រ |
| | | វិជ្ជមាន យេនឌ័របរិយាបន្ន និងការចូលរួមរបស់កុមារនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យនិងវិទ្យាល័យ | | | | |
| | | ៤.៣ ជ្រើសរើសមន្ត្រីទទួលបន្ទុកពង្រឹងសមត្ថភាពកិច្ចការពារកុមារនៅក្នុងប្រព័ន្ធផ្សព្វផ្សាយជាពិសេសការអនុវត្តត្រឹមត្រូវតាមក្រមសីលធម៌វិជ្ជាជីវៈ ផ្តោតលើការគោរពឯកជនភាពនិងរក្សាភាពថ្លៃថ្នូរដល់កុមារនិងគ្រួសារ | ៤៥,000 | ឆ្នាំ២០២២ | ក្រសួងព័ត៌មាន | ក្លឹបអ្នកកាសែតកម្ពុជា សមាគមទូរទស្សន៍និងវិទ្យុ ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| **គោលដៅទី៣.២.៥៖ ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង** | (៧)មន្ត្រីមានជំនាញមូលដ្ឋានក្នុងការគ្រប់គ្រងករណី | ៥.១ បណ្តុះបណ្តាលមន្ត្រីជំនាញដែលជាសមាជិក គ.ក.ស.ក និងគ.ក.ន.ក ក្នុងការជួយគ្រប់គ្រងករណី និងជួយសម្របសម្រួលភ្នាក់ងារសង្គមកិច្ចក្នុងការគ្រប់គ្រងករណី | ១២០,000 | ឆ្នាំ២០២២ ឆ្នាំ២០២៤ ឆ្នាំ២០២៧ | រដ្ឋបាល រាជធានីខេត្ត | ក្រសួង ស.អ.យ ក្រសួងកិច្ចការនារី ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | (៨)មន្ត្រីមានជំនាញក្នុងការគ្រប់គ្រងប្រព័ន្ធកិច្ចការពារកុមារ និងត្រួតពិនិត្យនូវសេវាថែទាំជំនួសចំពោះកុមារ | ៥.២ រៀបចំមេរៀននិងបណ្តុះបណ្តាលជាប្រចាំដល់សមាជិកគណកម្មាធិការពាក់ព័ន្ធនៅថ្នាក់ជាតិ និង គ.ក.ស.ក ថ្នាក់រាជធានីខេត្ត និងគ.ក.ស.ក ស្រុក ក្រុង ខណ្ឌ | ១៦០,000 | ឆ្នាំ២០២២ និងជាប្រចាំ | អគ្គលេខាការដ្ឋាន ក.ជ.ក រដ្ឋបាលរាជធានីខេត្ត | អគ្គលេខាធិកាដ្ឋាន ក.ជ.ក ដៃគូអភិវឌ្ឍន៍និង អង្គការសង្គមស៊ីវិល |
| | (៩)មន្ត្រីមានជំនាញកិច្ចការពារកុមារទៅតាមវិស័យ (អប់រំ សុខាភិបាល សុខុមាលគ្រួសារ ការជួញដូរមនុស្សនិងចំណាកស្រុក ការប្រឆាំងគ្រឿងញៀន និងការគ្រប់គ្រងគ្រោះមហន្តរាយ | ៥.៣ រៀបចំមេរៀននិងបណ្តុះបណ្តាលជាប្រចាំមន្ត្រីជំនាញទៅតាមវិស័យនីមួយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១៤០,000 | ឆ្នាំ២០២២ និងជាប្រចាំ | គណកម្មាធិការកុមារថ្នាក់ជាតិ ក.ជ.ក រាជធានីខេត្ត | ក្រសួងនិងស្ថាប័នទៅតាមវិស័យ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល |
| **ចំណាយសរុប** | | | **២,៦៣៥,000** | | | |

## ៤. តម្រូវការថវិកាសម្រាប់អនុវត្តផែនការ

ផែនការបណ្តុះបណ្តាលធនធានមនុស្សកិច្ចការពារកុមារនិងថ្លៃចំណាយ ២០២១-២០២៥ នេះរួមមានការប៉ាន់ប្រមាណថ្លៃចំណាយនៅក្នុងឧបសម្ព័ន្ធដែលនឹងជួយផ្តល់ជាព័ត៌មានមូលដ្ឋានសម្រាប់នីតិវិធីគណនាថ្លៃចំណាយក្នុងផែនការយុទ្ធសាស្រ្តថវិកា និងថវិកាកម្មវិធីប្រចាំឆ្នាំ។ ក្រសួងនឹងលើកសកម្មភាព និងគម្រោងចំណាយនៅក្នុងថវិកាកម្មវិធីសម្រាប់ថវិកាជាតិ និងស្នើសុំការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ ការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់សកម្មភាពរយៈពេលវែងប្រាំឆ្នាំ ជួយគាំទ្រដល់ការអនុវត្តតាមរយៈការជួយកំណត់ពីរបៀបក្នុងការវិភាជន៍ថវិកាដ៏ប្រសើរបំផុតនិងចាត់អាទិភាពទៅលើធនធានដែលមានកម្រិត និងតាមរយៈការកំណត់រកចន្លោះប្រហោងធនធានដើម្បីធ្វើការចង្អុលទិសចំពោះសកម្មភាពស្វែងរកមូលនិធិ។ ផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថ្លៃចំណាយត្រូវការថវិកាគាំទ្រប្រមាណ **២.៦៣៥.000 USD** ទាំងថវិការដ្ឋ និងថវិកាដៃគូ ។

## ៥. សេចក្តីសន្និដ្ឋាន

ការសម្រេចបានដោយជោគជ័យនូវការអនុវត្ត**ផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថ្លៃចំណាយ**ទាមទារនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នានិងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងស្ថាប័នពាក់ព័ន្ធនិងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់។ ទន្ទឹមនឹងនេះ ការវិភាជន៍ថវិកាសមស្របនឹងទាន់ពេលវេលាសម្រាប់គាំទ្រសកម្មភាពទាំងអស់ ដែលបានដាក់បញ្ចូលក្នុងតារាងម៉ាទ្រីស គឺជាលក្ខខណ្ឌដែលមិនអាចខ្វះបាន ចំពោះភាពជោគជ័យនៃការអនុវត្តផែនការនេះ។ ការសម្រេចបាននូវ**គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩** តាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍ធនធានមនុស្សនិងថ្លៃចំណាយនឹងរួមចំណែកធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកិច្ចការពារកុមារ និងសុខុមាលភាពកុមារជាពិសេសកុមាររងគ្រោះ និងងាយរងគ្រោះ។ល៕

## ផ្នែកទី៣៖ ផែនការត្រួតពិនិត្យ និងវាយតម្លៃ

### ១. សេចក្តីផ្តើម

លទ្ធផលរំពឹងទុកនៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្វើឱ្យប្រសើរឡើងសុខុមាលភាពកុមារ និងសិទ្ធិជាមូលដ្ឋានរបស់កុមារ នឹងត្រូវពិនិត្យឡើងវិញតាមរយៈការផ្តល់សេវាកិច្ចការពារកុមារ និងធានាបាននូវឧត្តមប្រយោជន៍របស់កុមារ។ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃសមស្របមួយគឺជាឧបករណ៍ដ៏សំខាន់សម្រាប់ជួយឱ្យយើងអាចសម្រេចបាននូវគោលដៅនិងទិសដៅ នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ តាមរយៈរបាយការណ៍ស្តីពីលទ្ធផលការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ ឆ្នាំ២០២១-២០២៥ និងដំណាក់កាលទី២ ឆ្នាំ២០២៦-២០២៩ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍធនធានមនុស្សនិងថ្លៃចំណាយ។ ដើម្បីតាមដានត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលសម្រេចបានពីការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចពារការកុមារប្រកបដោយប្រសិទ្ធភាពទាមទារឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបង្កើតនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃច្បាស់លាស់ដែលអាចអនុវត្តបាន។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីតាមដានត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារដូចមានចែងនៅក្នុងតារាងម៉ាទ្រីសនៃផែនការតាមដាននិងវាយតម្លៃ និងក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារនៅកម្ពុជា២០២០។

### ២. គោលបំណងនៃផែនការត្រួតពិនិត្យនិងវាយតម្លៃ

ផែនការនេះមានគោលបំណងបង្កើតក្របខ័ណ្ឌត្រួតពិនិត្យសូចនាករសម្រាប់វិស័យកិច្ចការពារកុមារនិងជាឧបករណ៍មួយសម្រាប់តាមដានវឌ្ឍនភាពកិច្ចការពារកុមារ ជាពិសេសលើកទឹកចិត្តភាគីពាក់ព័ន្ធឱ្យមកធ្វើការជាមួយគ្នាដើម្បីឆ្លើយតបនូវសំនួរខាងក្រោម៖

- តើផែនកាសកម្មភាពជំហាននីមួយៗកំពុងតែដំណើរការទៅតាមសកម្មភាព ដែរឬទេ ?
- តើផែនការសកម្មភាពនីមួយៗសម្រេចបាននូវចំណុចដៅនៃសូចនាករដែរឬទេ ?

ក្របខ័ណ្ឌនេះមានគោលបំណង៖

- ផ្តល់ក្របខ័ណ្ឌការងារមួយទាក់ទងនឹងការទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ ជាពិសេសផ្តល់នូវការណែនាំច្បាស់លាស់សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីប្រភេទព័ត៌មានដែលគួរប្រមូល និងរាយការណ៍ ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ និងវិភាគនៅថ្នាក់កណ្តាល។
- ផ្តល់នូវបញ្ជីរាយនាមអំពីសូចនាករស្នូលសម្រាប់តំណាងឱ្យវិស័យកិច្ចការពារកុមារ ប៉ុន្តែមិនទាន់គ្រប់ជ្រុងជ្រោយឡើយ។ ក្របខ័ណ្ឌការងារត្រួតពិនិត្យនេះគប្បីទទួលបានការបំពេញបន្ថែមពីក្របខ័ណ្ឌត្រួតពិនិត្យប្រតិបត្តិដែលចាំបាច់សម្រាប់ការរៀបចំកម្មវិធីលម្អិតជាងនេះនៅកម្រិតប្រតិបត្តិការ

គប្បីកត់សម្គាល់ថា ក្របខ័ណ្ឌការងារនេះមិនមានរាប់បញ្ចូលគោលដៅឡើយ។ ដូច្នេះ ទិន្នន័យដែលនឹងឆ្លងកាត់ក្របខ័ណ្ឌនេះ គប្បីត្រូវបានប្រើប្រាស់សំរាប់ការធ្វើលំហាត់ រៀបចំផែនការតាមវិស័យដើម្បីកំណត់គោលដៅ និងពេលវេលា។ ហេតុនេះ ក្របខ័ណ្ឌត្រួតពិនិត្យនេះ គប្បីត្រូវបានចាត់ទុកថាជាធាតុផ្សំមួយនៃយុទ្ធសាស្ត្រត្រួតពិនិត្យតាមដាន និងវាយតម្លៃទូលំទូលាយមួយ សម្រាប់វិស័យកិច្ចការពារកុមារដែលគប្បីអភិវឌ្ឍឱ្យមាននៅពេលអនាគត។ គោលបំណងនៃផែនការត្រួតពិនិត្យ និងវាយតម្លៃទៅលើកិច្ចការពារកុមារទូលំទូលាយ រួមមានដូចខាងក្រោម៖

- ផ្តល់នូវភស្តុតាងសុក្រឹតនិងគួរឱ្យជឿជាក់បានដែលបង្កលក្ខណៈឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្ត អាចកែសម្រួលជាបន្តបន្ទាប់នូវការផ្តល់សេវាកិច្ចការពារកុមារ ការអនុវត្តសកម្មភាពរបស់ខ្លួន ធាតុចេញយុទ្ធសាស្ត្រនិងដំណើរការក្នុងការសម្រេចឱ្យបាននូវលទ្ធផលការងារដែលចង់បាន និងដើម្បីបង្កើនកម្រិតវិសាលភាពដែលកម្ពុជាកំពុង

ខិតខំសម្រេចឱ្យបាននូវលទ្ធផលការងារផ្នែកកិច្ចការពារកុមារជាសកល ព្រមទាំងសម្របសម្រួលឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ឥរិយាបថ និងជំនឿរបស់តួអង្គសំខាន់ៗ។

- បង្កលក្ខណៈឱ្យរាជរដ្ឋាភិបាលកម្ពុជា និងតួអង្គ ព្រមទាំងវិស័យផ្សេងៗគ្នាដែលកំពុងចូលរួម អាចរៀនសូត្រថាតើសកម្មភាព លទ្ធផលរយៈពេលខ្លី លទ្ធផលរយៈពេលវែង យុទ្ធសាស្ត្រ និងដំណើរការណាខ្លះ ដែលទំនងនឹងមានឥទ្ធិពលធ្វើឱ្យមានភាពប្រសើរឡើងទៅលើសមិទ្ធិកម្ម និងសមធម៌នៃគោលបំណងកិច្ចការពារកុមារនៅកម្ពុជាជារួម ព្រមទាំងក្នុងនាមជាបុគ្គលដោយមិនប្រកាន់អំពីយេនឌ័រ និងពិការភាពឡើយ។

## ៣. យន្តការត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តផែនការត្រួតពិនិត្យ និងវាយតម្លៃ សម្រេចបានតាមគោលដៅយុទ្ធសាស្ត្រ ចង្កោមសកម្មភាព និងចំណុចដៅនៃសូចនាករដែលបានកំណត់។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាព។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារត្រូវបានធ្វើឡើងស្របតាមយន្តការ ដែលមានស្រាប់ដូចមានបង្ហាញក្នុងរូបភាពខាងក្រោម។

រូបភាពទី១៖ រចនាសម្ព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ




## ៤. កម្រងទិន្នន័យនៃសូចនាករ

ការប្រមូលទិន្នន័យសូចនាករទាំងនេះមានលក្ខណៈស្មុគស្មាញអាស្រ័យដោយក្រសួង ស្ថាប័នផ្សេងៗគ្នាមានប្រព័ន្ធព័ត៌មាន ដែលតម្រូវឱ្យមានការសម្របសម្រួលដើម្បីជួយបង្កើតឱ្យមានរូបភាពគ្រប់ជ្រុងជ្រោយអំពីកិច្ចការពារកុមារក្នុងកម្ពុជា។ បន្ថែមពីនេះទៀត ទិន្នន័យមួយចំនួនតម្រូវឱ្យរក្សាការសម្ងាត់ខ្ពស់។ កម្រងប្រមូលទិន្នន័យនៃការអនុវត្តគោលដៅទាំង៥ នៅក្នុងគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមាររួមមាន៖ ៣.២.១៖អភិវឌ្ឍនិងពង្រឹង

ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព ៣.២.២៖រៀបចំប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ ៣.២.៣៖អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ ៣.២.៤៖លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបទសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង ៣.២.៥៖ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង។ តារាងម៉ាទ្រីសនៃផែនការតាមដាននិងវាយតម្លៃផ្តោតលើធាតុផ្សំដូចខាងក្រោម៖

- ឈ្មោះសូចនាករ
- វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ
- ក្រសួងស្ថាប័នទទួលខុសត្រូវ
- ប្រភពទិន្នន័យ
- ទិន្នន័យមូលដ្ឋាន
- ទិន្នន័យចំណុចដៅ
- ក្រមខណ្ឌពេលវេលា
- តម្លៃសូចនាករ
- % លទ្ធផលសម្រេចបាន

## ៥. តម្រូវការថវិកាសម្រាប់អនុវត្តផែនការ

ផែនការត្រួតពិនិត្យ និងវាយតម្លៃត្រូវការថវិកាគាំទ្រប្រមាណ **៥៥0,000** USD ទាំងថវិការដ្ឋ និងថវិកាដៃគូ ដើម្បីចំណាយលើសកម្មភាពសិក្សា និងប្រមូលទិន្នន័យសូចនាករចំនួន៣៤ នៃប្រព័ន្ធកិច្ចការពារកុមារនិងគោលដៅ។

តារាងទី១៖ តម្រូវការថវិកាសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ

| ប្រព័ន្ធកិច្ចការពារកុមារ និងគោលដៅ | | ចំនួនសូចនាករ | តម្រូវការថវិកា (US$) |
|---|---|---|---|
| | ប្រព័ន្ធកិច្ចការពារកុមារ[57] | ៤ | ១00,000 |
| គោលដៅទី៣.២.១ | អភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព | ៥ | ៩0,000 |
| គោលដៅទី៣.២.២ | រៀបចំប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ | ៨ | ៩0,000 |
| គោលដៅទី៣.២.៣ | អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងជំនាញនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធ | ៦ | ៨៥,000 |
| គោលដៅទី៣.២.៤ | លើកកម្ពស់ការយល់ដឹងនិងផ្លាស់ប្តូរឥរិយាបទសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង | ៦ | ៩៥,000 |
| គោលដៅទី៣.២.៥ | ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង | ៥ | ៩0,000 |
| **សរុបថវិកាចំណាយ** | | **៣៤** | **៥៥0,000** |

[57] (១)ប្រព័ន្ធអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល (២)ប្រព័ន្ធសុខាភិបាល (៣)ប្រព័ន្ធសុខុមាលភាព និង(៤)ប្រព័ន្ធយុត្តិធម៌

## សូចនាករទាំង៣៤ នេះត្រូវបានរៀបចំទៅតាមប្រព័ន្ធកិច្ចការពារកុមារ និងគោលដៅទាំង៥ នៃគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩



# តារាងម៉ាទ្រីសនៃផែនការតាមដាននិងវាយតម្លៃ

| គោលបំណង និងគោលដៅ | | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ ប្រមូលទិន្នន័យ | ក្រសួងស្ថាប័ន ទទួលខុសត្រូវ | ប្រភព ទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌ ពេលវេលា | តម្លៃ សូចនាករ | % លទ្ធផល សម្រេចបាន |
| **គោលបំណង៖** លើកកម្ពស់កិច្ចការពារកុមារតាមរយៈការអនុវត្តប្រព័ន្ធកិច្ចការពារកុមារគ្រប់ជ្រុងជ្រោយនិងប្រទាក់ក្រឡាគ្នាពីគ្រប់ភាគីពាក់ព័ន្ធសំដៅឆ្លើយតបទៅនឹងកិច្ចការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់ទម្រង់ ដើម្បីឧត្តមប្រយោជន៍កុមារ | ១ | ប្រេវ៉ាឡង់នៃកុមារទទួលបានការសិក្សាអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ(ក)ភាគរយកុមារអាយុ៥ឆ្នាំទទួលបានការអប់រំកុមារតូចគ្រប់រូបភាព (មតេយ្យសិក្សារដ្ឋ សហគមន៍ ឯកជន) (ខ)អត្រាពិតនៃការសិក្សានៅបឋមសិក្សា (គ) អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (ឃ)អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ង)អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ(ច)អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ឆ)អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ជ)អត្រាកុមារបោះបង់ការសិក្សានៅបឋមភូមិ និងទុតិយភូមិទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ | ប្រមូលទិន្នន័យប្រចាំឆ្នាំពី ក.អ.យ.ក និងក.ក.ប.វ និង សិក្សាបង្កើតប្រព័ន្ធទិន្នន័យផ្លូវការ | ក.ជ.ក<br>វ.ជ.ស | ក.អ.យ.ក | (ក)៩៩.៣%<br>(ខ)៩៨.០%<br>(គ)៨៣.៣%<br>(ឃ)៦១.១%<br>(ង)៤៨.៩%<br>(ច)៣០.៩%<br>(ឆ)២៥.២%<br>(ជ)...% | (ក)...%<br>(ខ)...%<br>(គ)...%<br>(ឃ)...%<br>(ង)...%<br>(ច)...%<br>(ឆ)...%<br>(ជ)...% | ២០២៣<br>២០២៨ | កម្រិត៣ | ២០២៣<br>២០២៨ |
| | ២ | ប្រេវ៉ាឡង់នៃកុមារទទួលបានសេវាសុខាភិបាល៖(ក)ភាគរយនៃកុមារអាយុ១២-៥៩ខែ | ប្រមូលទិន្នន័យប្រចាំឆ្នាំពី ក.ស.ភ និងសិក្សាបង្កើតប្រព័ន្ធទិន្នន័យផ្លូវការ | ក.ជ.ក<br>វ.ជ.ស | ក.ស.ភ | (ក)៩៥%<br>(ខ)៨២%<br>(គ)៩៥%<br>(ឃ)...% | (ក)...%<br>(ខ)...%<br>(គ)...%<br>(ឃ)...% | ២០២៣<br>២០២៨ | កម្រិត៣ | ២០២៣<br>២០២៨ |

| គោលបំណង និងគោលដៅ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ | ក្រសួងស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌពេលវេលា | តម្លៃសូចនាករ | % លទ្ធផលសម្រេចបាន |
| | ទទួលបានវ៉ាក់សាំង៣ដូសបង្ការជំងឺ ខាន់ស្លាក់ ស្វិតដៃជើង តេតាណុស រលាកសួត (ខ)ភាគរយនៃកុមារទទួលបានថ្នាំទម្លាក់ព្រូន មេបង់ដាហ្សុលក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ (គ)ភាគរយនៃកុមារទទួលបានវ៉ាក់សាំងបង្ការកញ្ជ្រិល ស្អូចដូសទី១ (ឃ)ភាគរយនៃកុមាររងគ្រោះនិងងាយរងគ្រោះ[58]ទទួលបានសេវាសុខាភិបាល | | | | | | | | |
| | ៣ ប្រេវ៉ាឡង់នៃកុមារទទួលបានសេវាសុខុមាលភាព៖(ក)សមាមាត្រនៃកុមាររស់នៅក្រោមបន្ទាត់ភាពក្រីក្រ(ផ្អែកលើការប្រើប្រាស់) (ខ)សមាមាត្រនៃកុមាររស់នៅក្រោមបន្ទាត់ភាពក្រីក្រ(ផ្អែកលើពហុសមាសភាព) (គ)ភាគរយនៃកុមាររងគ្រោះនិងងាយរងគ្រោះដែលទទួលបានសេវាសុខុមាលភាព | ប្រមូលទិន្នន័យពី វ.ជ.ស/អ.ប.ស.ក និងសិក្សាបង្កើតប្រព័ន្ធទិន្នន័យផ្លូវការ | ក.ជ.ក<br>វ.ជ.ស | វ.ជ.ស/<br>អ.ប.ស.ក<br>ស.អ.យ | (ក)១២%<br>(ខ)៤១%<br>(គ)...% | (ក)...%<br>(ខ)...%<br>(គ)...% | ២០២៣<br>២០២៨ | កម្រិត៣ | ២០២៣<br>២០២៨ |

[58]គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ៖ កុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះមួយ ឬច្រើនប្រភេទដូចជា៖ កុមារកំព្រា កុមារដែលត្រូវបានបោះបង់ចោល កុមារដែលទទួលផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ (ជំងឺកាចសាហាវផ្សេងៗ) កុមារដែលទទួលរងការរំលោភបំពានផលូវភេទ រូបរាងកាយ ឬផ្លូវចិត្ត កុមារអនាថាតាមចិញ្ចើមថ្នល់ កុមារមានទំនាស់ជាមួយច្បាប់ កុមារដែលរង្គ្រោះ សារអំពើកេងប្រវ័ញ្ចផ្លូវភេទ (តាមអនឡាញ) ឬទំរង់ពលកម្មប្រកបដោយគ្រោះថ្នាក់ កុមារពិការ កុមារញៀនសារធាតុញៀន និងកុមារដែលមិនបានទទួលនូវតំរូវការផ្នែករូបវន្តជាមូលដ្ឋាន។

| គោលបំណង និងគោលដៅ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ ប្រមូលទិន្នន័យ | ក្រសួងស្ថាប័ន ទទួលខុសត្រូវ | ប្រភព ទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌ ពេលវេលា | តម្លៃ សូចនាករ | % លទ្ធផល សម្រេចបាន |
| | ៤ ប្រវាំឡង់នៃកុមារទទួលបានសេវាយុត្តិធម៌៖(ក)ភាគរយនៃកុមាររងអំពើហិង្សាផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត (ខ) ភាគរយនៃកុមាររងអំពើកេងប្រវ័ញ្ចផ្លូវភេទ(អនឡាញ) (គ)ភាគរយនៃកុមាររងពលកម្មធ្ងន់ធ្ងរ (ឃ)ភាគរយនៃកុមារមានទំនាស់ជាមួយច្បាប់ (ង)ភាគរយនៃកុមាររងអំពើជួញដូរមនុស្ស ដែលទទួលបានសេវាយុត្តិធម៌ | សិក្សាពីប្រព័ន្ធទិន្នន័យដែលគ្រប់គ្រងដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរៀបចំបង្កើតប្រព័ន្ធទិន្នន័យផ្លូវការ | ក.ជ.ក<br>វ.ជ.ស | ស.អ.យ<br>ក.ម.ផ<br>ក.ក.ប.វ<br>ក.យ.ធ<br>គ.ជ.ប.ជ | (ក)...%<br>(ខ)...%<br>(គ)...%<br>(ឃ)...%<br>(ង)...% | (ក)...%<br>(ខ)...%<br>(គ)...%<br>(ឃ)...%<br>(ង)...% | ២០២៣<br>២០២៨ | កម្រិត៣ | ២០២៣<br>២០២៨ |
| **គោលដៅទី៣.២.១៖អភិវឌ្ឍ**និងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធកិច្ចការពារកុមារឱ្យមានប្រសិទ្ធភាព | ៥ ភាគរយនៃកុមារ(បែងចែកតាមភេទ អាយុ ពិការភាព ជនជាតិដើមភាគតិច) ទំនាស់នឹងច្បាប់ ទទួលបានព័ត៌មាន សេវាពិគ្រោះយោបល់ និងជំនួយផ្នែកច្បាប់តាមទម្រង់កុមារមេត្រីនៅគ្រប់ជំហាននៃនីតិវិធីយុត្តិធម៌ | ប្រមូលទិន្នន័យដែលគ្រប់គ្រងដោយក្រសួងស្ថាប័នពាក់ព័ន្ធ និងសិក្សាបង្កើតប្រព័ន្ធទិន្នន័យផ្លូវការ | ក.ជ.ក<br>វ.ជ.ស | ក.អ.យ<br>ក.ម.ផ<br>ក.យ.ធ | ...% | ...% | ២០២៣<br>២០២៩ | កម្រិត២ | ២០២៣<br>២០២៨ |
| | ៦ ភាគរយនៃមន្ត្រីអនុវត្តច្បាប់នៅគ្រប់កម្រិតដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចការពារកុមារ | ការសិក្សាវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងក្រោយនៃគោលនយោបាយ | ក.ជ.ក | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ...% | ...% | ២០២៤<br>២០២៨ | កម្រិត២ | ២០២៤<br>២០២៨ |

| គោលបំណង និងគោលដៅ | ល.រ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ | ក្រសួងស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | ទិន្នន័យ មូលដ្ឋាន ២០១៩ | ទិន្នន័យ ចំណុចដៅ ២០២៩ | ការត្រួតពិនិត្យ (រយៈពេល) ក្រមខណ្ឌពេលវេលា | តម្លៃសូចនាករ | % លទ្ធផលសម្រេចបាន |
|---|---|---|---|---|---|---|---|---|---|---|
| | ៧ | ចំនួនច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចការពារកុមារត្រូវបានបង្កើតឡើង និងធ្វើវិសោធនកម្មស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ | កត់ត្រាពីរបាយការណ៍ក្រសួង ស្ថាប័ន និងទិន្នន័យរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី | ក.ជ.ក | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ៩ ច្បាប់[59] ៨ គោលន/ប[60] ...អនុក្រឹត្យ ...ប្រកាស | ...ច្បាប់ ..គោលន/ប ...អនុក្រឹត្យ ...ប្រកាស | ប្រចាំឆ្នាំ | កម្រិត១ | |
| | ៨ | ចំនួនវគ្គបណ្ដុះបណ្ដាល និងផ្សព្វផ្សាយពីខ្លឹមសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចការពារកុមារ | កត់ត្រាពីរបាយការណ៍ក្រសួងស្ថាប័នពាក់ព័ន្ធ | ក.ជ.ក | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ...វគ្គ ...ផ្សព្វផ្សាយ | ...វគ្គ ...ផ្សព្វផ្សាយ | ប្រចាំឆ្នាំ | កម្រិត១ | |
| | ៩ | អត្រាសមាមាត្រនៃកុមារបានចុះសំបុត្រកំណើត ឬបញ្ជាក់កំណើតដោយមិនគិតពីស្ថានភាពផ្លូវច្បាប់របស់ឪពុកម្ដាយឬកំព្រា | ការកត់ត្រាទិន្នន័យពីឃុំសង្កាត់និងពីគំហើញនៃការធ្វើផែនទីសេវាសង្គម | ក.ជ.ក | ក.ម.ផ | ...% | ៨០% | ប្រចាំឆ្នាំ | កម្រិត១ | |
| **គោលដៅទី៣.២.២៖** រៀបចំ និងអនុវត្តប្រព័ន្ធកិច្ចការពារកុមារឱ្យមានលក្ខណៈប្រទាក់ក្រឡាជាពហុវិស័យ | ១០ | ភាគរយនៃកុមាររងគ្រោះ(បែងចែកតាមភេទ អាយុ ជនជាតិដើមភាគតិច ពិការភាព)ទទួលបានផលប្រយោជន៍អំពីប្រព័ន្ធកិច្ចការពារកុមារជាលក្ខណៈ | បញ្ចូលក្នុងការវាយតម្លៃពាក់កណ្ដាលអាណត្តិ និងចុងក្រោយនៃគោលនយោបាយនិងការវិភាគជាមួយកុមារដែលទទួល | ក.ជ.ក វ.ជ.ស | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ...% | ៧៥% | ២០២៤ ២០២៩ | កម្រិត៣ | |

[59](១)ច្បាប់ស្ដីពីការងារ (២)ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន (៣)ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ (៤)ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ (៥) ច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ (៦)ច្បាប់ស្ដីពីពន្ធនាគារ (៧)ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន (៨)ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស (៩)ក្រមរដ្ឋប្បវេណី និង(១០)សេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារកុមារ

[60](១)គោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ (២)គោលនយោបាយជាតិស្ដីពីសុខភាពសិក្សា (៣)គោលនយោបាយជាតិស្ដីពីគាំពារ និងអភិវឌ្ឍន៍កុមារតូច (៤)ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (៥) គោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ (៦)គោលនយោបាយវត្តស័ង្គហកុមារ (៧)គោលនយោបាយស្ដីពីការអប់រំបរិយាបន្ន (៨)គោលនយោបាយ_«ភូមិ_ឃុំ_សង្កាត់មានសុវត្ថិភាព»

| គោលបំណង និងគោលដៅ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ | ក្រសួងស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌពេលវេលា | តម្លៃសូចនាករ | % លទ្ធផលសម្រេចបាន |
| | ប្រទាក់ក្រឡាជាពហុវិស័យមានការកើនឡើង | ផលប្រយោជន៍ដោយវិធីសាស្ត្រកុមារមេត្រី | | | | | | | |
| | ១១ ភាគរយមន្ត្រីនៃក្រសួងស្ថាប័នពាក់ព័ន្ធដែលបានអនុវត្តត្រឹមត្រូវតាមតួនាទីនិងគោលការណ៍នៃកិច្ចការពារកុមារ | បញ្ចូលក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងក្រោយនៃគោលនយោបាយ | ក.ជ.ក<br>វ.ជ.ស | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...% | ៨០% | ២០២៤<br>២០២៩ | កម្រិត៣ | |
| | ១២ ភាគរយនៃក្រសួងស្ថាប័នជាសមាជិក ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានពេញចិត្តនឹងគណៈកម្មការការពារកុមារថ្នាក់ជាតិ | កិច្ចប្រជុំពិភាក្សា និងសម្ភាសជាមួយអ្នកពាក់ព័ន្ធ | ក.ជ.ក | សមាជិក គ.ក.ជ | ...% | ៧០% | ២០២៤<br>២០២៩ | កម្រិត២ | |
| | ១៣ ប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយត្រូវបានអនុវត្ត និងផ្សារភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យទៅតាមវិស័យពាក់ព័ន្ធ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ CPMIS | ក.ជ.ក<br>ស.អ.យ | ស.អ.យ | រៀបចំបង្កើតប្រព័ន្ធ CPMIS | ដំណើរការ ១០០% | ២០២២ | កម្រិត២ | |
| | ១៤ ភាគរយនៃធនធាន(មនុស្ស និងថវិកា)សម្រាប់កិច្ចការពារកុមារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិមានការកើនឡើង | ស្រង់ទិន្នន័យធនធានពីស្ថាប័នពាក់ព័ន្ធ និង ក.ស.ហ និង គ.ជ.អ.ប | ក.ជ.ក | ក.ស.ហ<br>គ.ជ.អ.ប<br>iSAF Data base | ...% | កើនឡើង ៧០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ១៥ ចំនួនអ្នកទទួលបន្ទុកកុមារនៅតាមឃុំ សង្កាត់មានកើនកើនឡើង | ស្រង់ទិន្នន័យធនធានមនុស្សពី ក.ម.ផ | ក.ជ.ក | ក.ម.ផ | ៨២៣នាក់[61] | ១៦៤៦នាក់ | ប្រចាំឆ្នាំ | កម្រិត១ | |

[61] បច្ចុប្បន្នមានអ្នកទទួកបន្ទុកកិច្ចការនារី និងកុមារចំនួន ១៦៤៦នាក់ ពោលគឺអ្នកទទួលបន្ទុកម្នាក់ធ្វើការងារច្រើនមុខ គោលដៅគឺស្នើសុំបង្កើនអ្នកទទួលបន្ទុកកុមារ១នាក់គ្រប់ ១៦៤៦ ឃុំសង្កាត់

| គោលបំណង និងគោលដៅ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ | ក្រសួងស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌពេលវេលា | តម្លៃសូចនាករ | % លទ្ធផលសម្រេចបាន |
| | ១៦ ភាគរយនៃករណីកុមារដែលសម្របសម្រួលឆ្លើយតបដោយ គ.ក.ន.ក និង គ.ក.ស.ក បានអនុវត្តស្របតាមនីតិវិធីត្រឹមត្រូវ | ដកស្រង់ពីរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារនៅតាមរាជធានី ខេត្ត | ក.ជ.ក | ក.ម.ផ<br>រ.ថ.ជ | ...% | ៧០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ១៧ ចំនួនករណីកុមារទទួលបានអន្តរាគមន៍ពីប្រព័ន្ធកិច្ចការពារកុមារនៅតាមស្ថានតំណាងប្រទេសកម្ពុជា | ដកស្រង់ពីរបាយការណ៍វឌ្ឍនភាពពីស្ថានតំណាងប្រទេសកម្ពុជាស្តីពីកិច្ចការពារកុមារ | អគ្គរាជទូតនៅស្ថានតំណាងប្រទេសកម្ពុជា | កបទ.សអ | ...ករណី | ...ករណី | ប្រចាំឆ្នាំ | កម្រិត១ | |
| **គោលដៅទី៣.២.៣៖** អភិវឌ្ឍធនធានមនុស្សក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំនាញនៅគ្រប់របនាសម្ព័ន្ធពាក់ព័ន្ធ | ១៨ ភាគរយនៃមន្ត្រីអនុវត្តច្បាប់ មន្ត្រីផ្តល់សេវា និងបុគ្គលិកសង្គមកិច្ចទៅតាមភូមិសាស្ត្រ (កម្រិតក្រុង ស្រុក ខណ្ឌ និង ឃុំសង្កាត់)មានការកើនឡើង | បង្កើតទម្រង់ប្រមូលទិន្នន័យពី ក.អ.យ ក.ម.ផ និង រ.ថ.ជ | ក.ជ.ក<br>គ.ក.ជ | ស.អ.យ<br>ក.ម.ផ | ...% | ៧០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ១៩ ភាគរយនៃមន្ត្រីអនុវត្តច្បាប់នៅគ្រប់កម្រិតបានអនុវត្តត្រឹមត្រូវតាមបទដ្ឋាននិងគោលការណ៍ជាតិនិងអន្តរជាតិឆ្លើយតបទៅនឹងករណីកិច្ចការពារកុមារ | បញ្ចូលក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងក្រោយនៃគោលនយោបាយ | ក.ជ.ក<br>គ.ក.ជ | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ...% | ៦៥% | ២០២៣<br>២០២៨ | កម្រិត២ | |
| | ២០ ភាគរយនៃមន្ត្រីអនុវត្តច្បាប់ ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកកិច្ចការពារកុមារទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញ | បញ្ចូលក្នុងការវាយតម្លៃពាក់កណ្តាលពេល និងចុងក្រោយនៃគោលនយោបាយ | ក.ជ.ក<br>គ.ក.ជ | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | ...% | ៧០% | ២០២៣<br>២០២៨ | កម្រិត៣ | |

| គោលបំណង និងគោលដៅ | | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ | ក្រសួងស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌពេលវេលា | តម្លៃសូចនាករ | % លទ្ធផលសម្រេចបាន |
| | ២១ | ភាគរយកម្មវិធីសិក្សាស្តីពីកិច្ចការពារកុមារនៅតាមគ្រឹះស្ថានអប់រំជាតិត្រូវបានបង្កើត | បញ្ចូលទៅក្នុងទម្រង់របាយការណ៍ពីគ្រឹះស្ថានអប់រំ | ក.ជ.ក<br>ក.អ.យ.ក | ក.អ.យ.ក<br>គ្រឹះស្ថានអប់រំ | ...% | ៧០% | ២០២២<br>ប្រចាំឆ្នាំ | កម្រិត២ | |
| | ២២ | ភាគរយភ្នាក់ងារសង្គមកិច្ច មន្ត្រីនគរបាល កងរាជអាវុធហត្ថ ជាស្ត្រី និងអ្នកទទួលបន្ទុកដាក់លាក់លើករណីកុមារនៅតាមតុលាការ | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារប្រចាំឆ្នាំ | ក.ជ.ក | ស.អ.យ<br>ក.ម.ផ<br>ក.ក.ជ<br>ក.យ.ធ | ...% | ៧៥% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ២៣ | ភាគរយមន្ត្រីទទួលបានការបណ្តុះបណ្តាលពីយុទ្ធសាស្ត្រ INSPIRE | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារប្រចាំឆ្នាំ | ក.ជ.ក<br>គ.ក.ជ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...% | ៧០% | ប្រចាំឆ្នាំ | កម្រិត១ | |
| **គោលដៅទី៣.២.៤៖** លើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារនៅគ្រប់ទីកន្លែង | ២៤ | ភាគរយនៃសាធារណជនរួមទាំងកុមារបានយល់ដឹងអំពីការប្រព្រឹត្តិបែបវិជ្ជមានចំពោះកុមារបានកើតឡើង(បែងចែកតាមភេទ អាយុ តាមតំបន់) | បញ្ចូលក្នុងការវាយតម្លៃពាក់កណ្តាលពេល និងចុងក្រោយនៃគោលនយោបាយ | ក.ជ.ក<br>គ.ក.ជ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...% | ៧០% | ២០២៣<br>២០២៨ | កម្រិត៣ | |
| | ២៥ | ភាគរយនៃកុមារ(បែងចែកតាមអាយុ ភេទ ពិការភាព ជនជាតិដើមភាគតិច) នៅក្នុងគ្រួសារ សាលារៀន មណ្ឌលយុវនីតិសម្បទា មណ្ឌលថែទាំ និងថែទាំកុមារតាមសហគមន៍បានទទួលរងការប្រព្រឹត្តិជាវិជ្ជមានពីមន្ត្រី គ្រូបង្រៀននិងអ្នកថែទាំ | សិក្សាវាយតម្លៃ និងធ្វើកិច្ចសម្ភាសឬពិភាក្សាជាមួយកុមារដោយប្រើវិធីកុមារមេត្រី | ក.ជ.ក | ស.អ.យ<br>ក.អ.យ.ក | ...% | ៧៥% | ២០២៣<br>២០២៨ | កម្រិត៣ | |

| គោលបំណង និងគោលដៅ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ | ក្រសួងស្ថាប័នទទួលខុសត្រូវ | ប្រភពទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌពេលវេលា | តម្លៃសូចនាករ | % លទ្ធផលសម្រេចបាន |
| | ២៦ ភាគរយនៃក្រសួងស្ថាប័នមានការយល់ដឹងអំពី Cambodia Protect, ការចិញ្ចឹមកូនតាមបែបវិជ្ជមាន និងការអប់រំតាមបែបវិជ្ជមាននៅតាមសាលារៀន | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារប្រចាំឆ្នាំ | ក.ជ.ក | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...% | ៧០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ២៧ ភាគរយនៃធនជានឃុំសង្កាត់គាំទ្រសកម្មភាពកិច្ចការពារកុមារដែលដឹកនាំដោយកុមារ និងយុវជន | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារប្រចាំឆ្នាំ | ក.ជ.ក | ក.ម.ផ | ...% | ៦០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ២៨ ចំនួនផែនការគាំទ្រការផ្លាស់ប្តូរឥរិយាបថការក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារក្នុងវិស័យសាសនា សារព័ត៌មាន ការថែទាំជំនួសចំពោះកុមារ ប្រព័ន្ធអនឡាញ និងជនជាតិដើមភាគតិច | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារប្រចាំឆ្នាំ | ក.ជ.ក | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...ផែនការ | ...ផែនការ | ប្រចាំឆ្នាំ | កម្រិត១ | |
| | ២៩ ចំនួនការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងកិច្ចការពារកុមារដែលផ្តួចផ្តើមដោយអ្នកស្រាវជ្រាវ និស្សិតនិងក្រុមនៅសហគមន៍ | បង្កើតទម្រង់របាយការណ៍កត់ត្រាប្រចាំឆ្នាំនិងធ្វើឱ្យអ្នកពាក់ព័ន្ធដើម្បីបំពេញ និងផ្ញើត្រឡប់ | ក.ជ.ក | ក.ជ.ក<br>ស.អ.យ<br>គ្រឹះស្ថានអប់រំ | ...អត្ថបទ | ...អត្ថបទ | ប្រចាំឆ្នាំ | កម្រិត១ | |
| **គោលដៅទី៣.២.៥៖** ផ្តល់កិច្ចការពារកុមារឱ្យសមស្របតាមស្ថានភាពជាក់ស្តែង | ៣០ ភាគរយនៃកុមាររងគ្រោះទទួលបានសេវាជាលក្ខណៈប្រមូលផ្តុំនៅមួយកន្លែងទោះក្នុងស្ថានភាពគ្រោះមហន្តរាយ | បញ្ចូលក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងក្រោយនៃគោលនយោបាយ | ក.ជ.ក<br>គ.ក.ជ | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...% | ៧០% | ២០២៤<br>២០២៩ | កម្រិត៣ | |

| គោលបំណង និងគោលដៅ | សូចនាករ | វិធីសាស្ត្រនិងឧបករណ៍ ប្រមូលទិន្នន័យ | ក្រសួងស្ថាប័ន ទទួលខុសត្រូវ | ប្រភព ទិន្នន័យ | ទិន្នន័យ | | ការត្រួតពិនិត្យ (រយៈពេល) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | មូលដ្ឋាន ២០១៩ | ចំណុចដៅ ២០២៩ | ក្រមខណ្ឌ ពេលវេលា | តម្លៃ សូចនាករ | % លទ្ធផល សម្រេចបាន |
| | ៣១ ប្រព័ន្ធគ្រប់គ្រងករណីកុមារត្រូវបានអភិវឌ្ឍន៍និងអនុវត្តតាមប្រព័ន្ធឌីជីថល | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារ | ក.ជ.ក | ស.អ.យ | រៀបចំបង្កើត 0% | ដំណើរការ ១០០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ៣២ ភាគរយនៃករណីកុមារដែលបានបញ្ជូនទៅរកសេវាបន្ថែមពីប្រព័ន្ធរាយការណ៍បន្ទាន់ និងប្រព័ន្ធទូរសព្ទជំនួយទាន់ពេល | រួមបញ្ចូលជាមួយប្រព័ន្ធរបាយការណ៍ស្តីពីស្ថានភាពកិច្ចការពារកុមារ | ក.ជ.ក | ស.អ.យ ក.ម.ផ | ...% | ៧០% | ប្រចាំឆ្នាំ | កម្រិត១ | |
| | ៣៣ ចំនួនទីតាំងផ្តល់សេវាកិច្ចការពារកុមារជាកញ្ចប់នៅតាមមូលដ្ឋានត្រូវបានបង្កើត | បញ្ចូលទៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំពីកិច្ចការពារកុមារ | ក.ជ.ក | ក្រសួងស្ថាប័នពាក់ព័ន្ធ | ...ទីតាំង | ...ទីតាំង | ប្រចាំឆ្នាំ | កម្រិត២ | |
| | ៣៤ គោលនយោបាយឆ្លើយតបគ្រោះមហន្តរាយត្រូវបានបង្កើតនិងអនុវត្តស្របតាមបទដ្ឋានអប្បបរមានៃកិច្ចការពារកុមារនៅក្នុងសកម្មភាពមនុស្សធម៌ | ដកស្រង់ពីរបាយការណ៍ឆ្លើយតបគ្រោះមហន្តរាយ និងវិភាគលើឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយដូចជាផែនការឆ្លើយតបអន្តរាគមន៍ និងសមាហរណកម្មបន្ទាប់ពីគ្រោះមហន្តរាយ | គ.គ.ម | គ.គ.ម | រៀបចំបង្កើត 0% | ដំណើរការ ១០០% | ២០២២ ប្រចាំឆ្នាំ | កម្រិត២ | |
| | | | | | | | | | |